ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦

នៅក្នុងឆ្នាំ២០២៥នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្ដល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម៖**
  - ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២១លើក ដើម្បី៖
    - ១- ពិនិត្យ និងសម្រេចលើសេចក្ដីស្នើច្បាប់ និងសេចក្ដីព្រាងច្បាប់ ចំនួន៤៤ច្បាប់។
    - ២- ពិនិត្យ និងសម្រេចលើរបាយការណ៍សង្ខេបស្ដីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣, លើកទី៣ និងទី៤ នីតិកាលទី៥។
    - ៣- ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ ០០៩/០៥២៥/លគ.គក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៥ និងលេខ ០១១/០៥២៥/លគ.គក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៥។
    - ៤- ពិនិត្យ និងសម្រេចលើការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ ព្រឹទ្ធសភា នីតិកាលទី៥។
    - ៥- ពិនិត្យ និងសម្រេចលើសុពលភាពបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ១រូប តំណាងព្រឹទ្ធសភាទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។

៦- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង

៧- កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងសម័យប្រជុំលើកទី៤ នីតិកាលទី៥។

❖ សម័យប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន១២លើក ដែលមានរបៀបវារៈ ដូចខាងក្រោម៖

១- ពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី សញ្ជាតិ។

៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការអភិរក្ស និងជីវៈចម្រុះសមុទ្រប្រកបដោយចីរភាព នៅក្រៅដែនយុត្តាធិការជាតិ ក្រោមអនុសញ្ញាសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ។

៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើសន្ធិសញ្ញាស្តីពី តំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ។

៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។

៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។

១០- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ជលផល។

១១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ក្របខណ្ឌបទប្បញ្ញត្តិសុវត្ថិភាពម្ហូបអាហារអាស៊ាន។

១២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានស្តីពី បម្លាស់ទីរូបវន្តបុគ្គល។

១៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី១ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន។

១៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២

ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់។
១៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពី ការបង្កើតអង្គការអន្តរជាតិសម្រាប់សន្ទានកម្ម។
១៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
១៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។
១៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។
១៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីនស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។
២០- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី២ដើម្បីធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរីស្តីពី ការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។
២១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន បានយ៉ាន អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។
២២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន វេ សាន់ ស៊ី.អេ.ភី យូណាយធីត អ៊ិនវេសម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តបាត់ដំបង។
២៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ផេល ប្លូ ដត ឌីវេឡុបម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១២០មេហ្គាវ៉ាត់ នៅខេត្តព្រៃវែង។
២៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន អេនើវើស ឯ.ក សម្រាប់

គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ៣៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

២៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន វីស៊ីលាន មិរ៉ាយ ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ១០០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

២៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន សិនកែ ភីវី អ៊ិនវេសម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ។

២៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន តាំង ឡៃស៊ី អ៊ីមផត អិចផត សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព ៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

២៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប ផៅវ័ឌូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព២០០មេហ្គាវ៉ាត់ នៅខេត្តស្ទឹងត្រែង។

២៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆេមពាន គ្រុប ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនី ដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

៣០- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ប៊ីលហ្វ្រេត ខនស្រ្តាក់សិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៣៥០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

៣១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ច័ន្ទ និមល ឌីវេឡុបម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តកំពង់ចាម។

៣២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ម៉ឌើនីធី ហូលឌីង សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព

១០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។

៣៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន អេច ខេ អូអេស៊ីស ផៅវ៉ែ អេនើជី ឌីវេឡុបម៉ិន ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

៣៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្ទេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព ១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

៣៥- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឥណ្ឌូឆាយណា វីនផៅវ៉ែ ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

៣៦- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន លីឌើរ វីន អេនើជី (ខេមបូឌា) ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

៣៧- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន គោព្រៃ វីនហ្វាម ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព ១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

៣៨- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន បេជីង ហ្វេងហ្គ័ង អ៊ិនហ្វីនីត វីន អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់ នៅខេត្តមណ្ឌលគិរី។

៣៩- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន អេសភីអេចភី (ខេមបូឌា) ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយថាមពលជីវម៉ាស អានុភាព ៥០មេហ្គាវ៉ាត់ និងស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព ៤០មេហ្គាវ៉ាត់ ផ្គួបគ្នា នៅខេត្តកំពង់ស្ពឺ។

៤០- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន បុទុម សាគរ អេនើជី ឯ.ក សម្រាប់គម្រោងវិនិយោគស្ថានីយផលិតអគ្គិសនីដើរដោយឧស្ម័នធម្មជាតិ អានុភាព

៩០០មេហ្គាវ៉ាត់ នៅខេត្តកោះកុង។

៤១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន អេនើស៊ួរ ឯ.ក សម្រាប់គម្រោងវិនិយោគវារីអគ្គិសនីព្រែកល្ពាង១ និង២ អានុភាព១១០មេហ្គាវ៉ាត់ នៅខេត្តរតនគិរី។

៤២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្មេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយប្រព័ន្ធអាគុយស្តុកទុកថាមពល អានុភាព២០០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់ និងអានុភាព៣០០មេហ្គាវ៉ាត់ នៅខេត្តកំពង់ឆ្នាំង។

៤៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ស្មេថេក ខូ អិលធីឌី សម្រាប់គម្រោងវិនិយោគស្ថានីយប្រព័ន្ធអាគុយស្តុកទុកថាមពល អានុភាព៥០០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់។

៤៤- ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុន ឆាយណា ណេសិនណល ហៅរី ម៉ាស៊ីនើរី សម្រាប់គម្រោងវិនិយោគវារីអគ្គិសនីបូមទឹកស្តុកទុក អានុភាព១០០០មេហ្គាវ៉ាត់ នៅខេត្តកោះកុង។

៤៥- ស្ដាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្ដីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣, លើកទី៣ និងលើកទី៤ នីតិកាលទី៥។

៤៦- បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកិច្ចការនារី និង

៤៧- ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។

❖ កិច្ចប្រជុំលើកទី១ និងលើកទី២ នៃគណៈកម្មាធិការសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

❖ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានរដ្ឋសភា។

❖ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បិទសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ នៅវិមានរដ្ឋសភា។

❖ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល និងតំណាងក្រុមតំណាងរាស្ត្រហត្ថលេខី ដើម្បីពិនិត្យសិក្សាលើសេចក្ដីស្នើច្បាប់ និងសេចក្ដីព្រាងច្បាប់ ចំនួន ៤៤ច្បាប់។

- ❖ ប្រជុំគណៈកម្មការពិសេស ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និង
- ❖ ប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យឆ្លងសេចក្តីព្រាងសេចក្តីសម្រេចស្តីពី តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការទាំង១០ ព្រឹទ្ធសភា។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**
  - ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
    - បានអញ្ជើញចូលរួមរៀបចំ និងធ្វើសន្និសីទសារព័ត៌មានរួម អំពីលទ្ធផលសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ នៅវិមានរដ្ឋសភា។
    - បានអញ្ជើញចូលរួមក្នុងពិធីសច្ចាប្រណិធានចូលកាន់តំណែងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ សម្រាប់អាណត្តិទី៤ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង និង
    - បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព) លើកទី១ ទី៣ និងទី៤ អាណត្តិទី៤ នៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន៤លើក។

## ២-មុខងារតាមដានការអនុវត្តច្បាប់

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារ និងចុះបេសកកម្ម ចំនួន៤៥លើក នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖**
  - ❖ គណៈកម្មការទី១ព្រឹទ្ធសភា ចំនួន២លើក៖
    - អញ្ជើញចុះបំពេញបេសកកម្មដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ការដោះស្រាយពាក្យបណ្តឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ នៅខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប និង
    - អញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយ **ឯកឧត្តម ម៉េត មករា** អនុប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ(ក.ស.ជ) និងជារដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារទាក់ទងនឹងការលើកកម្ពស់សិទ្ធិជនពិការ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - ❖ គណៈកម្មការទី២ព្រឹទ្ធសភា ចំនួន៦លើក៖
    - អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដោយផ្តោតលើថវិកាថ្នាក់ក្រោមជាតិ បញ្ហាប្រឈម និងសំណូមពរ នៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។
    - អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់ខេត្តព្រះសីហនុ កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកិច្ចការពាក់ព័ន្ធក្នុងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តព្រះសីហនុ។
    - អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ស៊ុំ សន្និសិទ្ធ** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងវិស័យធនាគារ នៅធនាគារជាតិនៃកម្ពុជា។

- អញ្ជើញជួបពិភាក្សាការងារជាមួយ **លោកជំទាវបណ្ឌិត សោម គឹមសួគ៌** អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់អាជ្ញាធរសវនកម្មជាតិ បេសកកម្ម ចក្ខុវិស័យ ឱកាស និងបញ្ហាប្រឈមនានា ជាពិសេសបង្កើនកិច្ចសហការការងារ នៅទីស្តីការអាជ្ញាធរសវនកម្មជាតិ។
- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមបណ្ឌិត គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ចក្ខុវិស័យ ផែនការយុទ្ធសាស្ត្រ ការប្រមូលពន្ធគយ និងបញ្ហាប្រឈមនានា ជាពិសេសបង្កើនកិច្ចសហការការងារ នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង
- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារ ចក្ខុវិស័យ ផែនការយុទ្ធសាស្ត្រ ការប្រមូលពន្ធ និងបញ្ហាប្រឈម ជាពិសេសបង្កើនកិច្ចការងារ នៅអគ្គនាយកដ្ឋានពន្ធដារ។

❖ គណៈកម្មការទី៣ព្រឹទ្ធសភា ចំនួន៣លើក៖

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានរបស់អាជ្ញាធរខេត្តព្រះសីហនុ ពាក់ព័ន្ធទៅនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៣ព្រឹទ្ធសភា នៅខេត្តព្រះសីហនុ។
- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមឆ្នាំ២០២៤ និងចក្ខុវិស័យរបស់ក្រសួងធនធានទឹក និងឧតុនិយមឆ្នាំ២០២៥ នៅទីស្តីការក្រសួង និង
- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនានាកន្លងមក និងចក្ខុវិស័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅទីស្តីការក្រសួង។

❖ គណៈកម្មការទី៤ព្រឹទ្ធសភា ចំនួន៥លើក៖

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់របស់អាជ្ញាធរខេត្តព្រះវិហារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលើកិច្ចប្រតិបត្តិការរបស់ខេត្ត។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងការអនុវត្តច្បាប់ និងតុលាការ របស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ នៅខេត្តស្វាយរៀង។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីពិភាក្សាការងារជាមួយឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ មន្ទីរជំនាញជុំវិញខេត្ត និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងខេត្តរតនគិរី នៅសាលមហោស្រពរតនៈ ខេត្តរតនគិរី។

- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងទិសដៅការងារបន្ត របស់ក្រសួងឆ្នាំ២០២៥ នៅទីស្តីការក្រសួងមហាផ្ទៃ និង
- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងទិសដៅការងាររបស់ក្រសួងឆ្នាំ២០២៥ នៅទីស្តីការក្រសួងការពារជាតិ។

❖ គណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន៤លើក។

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីពិភាក្សាការងារជាមួយរដ្ឋបាលខេត្តព្រះសីហនុ និងរដ្ឋបាលខេត្តកំពត។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ជាគ្រឿងឧបភោគ បរិភោគ និងថវិកាចែកជូនជនភៀសសឹក ចំនួន៤០០គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលសុវត្ថិភាពនៅវត្តព្រះពុទ្ធមានជ័យ ហៅវត្តប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីពិភាក្សាការងារជាមួយ **ឯកឧត្តម ញ៉ែម សំអឿន** អភិបាលនៃគណៈអភិបាលខេត្តរតនគិរី នៅខេត្តរតនគិរី និង
- **ឯកឧត្តមឧត្តមសេនីយ៍ឯក សុខ វាសនា** អគ្គនាយកអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ ធ្វើសេចក្តីរាយការណ៍អំពីការងារសំខាន់ៗ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

❖ គណៈកម្មការទី៦ព្រឹទ្ធសភា ចំនួន៣លើកៈ

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមមូលដ្ឋាន អំពីការពង្រឹងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ការចុះបញ្ជីកំណើត បញ្ជីមរណភាព និងបញ្ជីអាពាហ៍ពិពាហ៍ជូនប្រជាពលរដ្ឋ នៅខេត្តស្វាយរៀង។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីពិភាក្សាការងារជាមួយសាលាដំបូង និងអយ្យការអមសាលាដំបូង ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ នៅខេត្តស្វាយរៀង និង
- អញ្ជើញពិភាក្សាការងារជាមួយនឹងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីឈ្វេងយល់ប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ ការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ បញ្ហាប្រឈមនានា ដែលសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ជួបប្រទះពេលអនុវត្តការងារ នៅសាលប្រជុំសាលាឧទ្ធរណ៍រាជធានីភ្នំពេញ

❖ គណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន២លើកៈ

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម

វិធានការដោះស្រាយ និងចក្ខុវិស័យពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង និង

- អញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យ របស់ក្រសួង នៅសាលប្រជុំក្រសួងទេសចរណ៍។

❖ គណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន៧លើកៈ

- អញ្ជើញចុះបេសកកម្ម ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការនៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីជួបសំណេះសំណាលជាមួយអាជ្ញាធរមានសមត្ថកិច្ច និងពិនិត្យស្ថានភាពនៃការវិលត្រឡប់របស់ពលករខ្មែរ នៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ច្រកទ្វារព្រំដែនអន្តរជាតិដូង ខេត្តបាត់ដំបង និងច្រកទ្វារព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន។
- អញ្ជើញចុះទស្សនកិច្ច និងជួបសំណេះសំណាលជាមួយសិប្បករតម្បាញហូល ផាមួង ក្រមា សារុងសូត្រ នៅខេត្តតាកែវ និងគណៈកម្មការសហគមន៍នេសាទត្រពាំងរពៅ នៅខេត្តកំពត។
- អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹក នៅមណ្ឌលសុខភាពគូលែន និងមណ្ឌលសុវត្ថិភាពវត្តឧត្តមគិរីទួលអណ្តែត ខេត្តព្រះវិហារ និងចែកចង្រ្កានសន្សំសំចៃថាមពលជូនប្រជាពលរដ្ឋ នៅខេត្តកំពង់ធំ។
- អញ្ជើញចុះសួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពល សារុង និងក្រមា ចែកជូនប្រជាពលរដ្ឋ នៅខេត្តកំពង់ធំ ព្រមទាំងនាំយកព្រះរាជអំណោយគ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ និងថវិកា ជូនកងពលតូចអន្តរាគមន៍លេខ៩ និងគ្រួសារកងទ័ពជួរមុខប្រចាំទិសមុំបី នៅខេត្តព្រះវិហារ និង
- អញ្ជើញចុះសួរសុខទុក្ខ និងនាំយកព្រះរាជអំណោយ ថ្នាំពេទ្យ គ្រឿងឧបភោគ បរិភោគ សម្ភារប្រើប្រាស់ ចំនួន២លើក ជូនវីរកងទ័ពជួរមុខប្រចាំទិសមុំបី នៅខេត្តព្រះវិហារ។

❖ គណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន៨លើកៈ

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីដំណើរការប្រតិបត្តិនៃទំនប់វារីអគ្គិសនីសេសានក្រោម២ ព្រមទាំងពិនិត្យវឌ្ឍនភាពការងារដែលអាជ្ញាធរខេត្តសម្រេចបាន បញ្ហាប្រឈម និងផែនការសកម្មភាពរបស់អាជ្ញាធរខេត្ត និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព នៅខេត្តស្ទឹងត្រែង។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីដំណើរការស្ថានីយផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ព្រមទាំងពិនិត្យវឌ្ឍនភាពការងារដែលអាជ្ញាធរខេត្ត

សម្រេចបាន បញ្ហាប្រឈម និងផែនការសកម្មភាពរបស់អាជ្ញាធរខេត្ត និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព នៅខេត្តកំពង់ស្ពឺ។

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីទទួលព័ត៌មានអំពីសភាពការណ៍ថ្មីៗ និងពិភាក្សាការងារជាមួយរដ្ឋបាលខេត្តស្វាយរៀង ខេត្តព្រៃវែង នៅសាលាខេត្ត។
- អញ្ជើញចុះទស្សនកិច្ចសិក្សាឈ្វេងយល់អាកាសយានដ្ឋានអន្តរជាតិតេជោ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និង
- អញ្ជើញជួបពិភាក្សាការងារជាមួយវិទ្យាស្ថាន ចំនួន៤៖ ទី(១)វិទ្យាស្ថានជាតិវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍, ទី(២)វិទ្យាស្ថានតេជោសែន សាធារណការ និងដឹកជញ្ជូន, ទី(៣)វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ និងទី(៤)វិទ្យាស្ថានអភិបាលកិច្ចឌីជីថលនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពវិទ្យាស្ថានពាក់ព័ន្ធទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រ ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស បញ្ហាប្រឈម ដំណោះស្រាយ និងទិសដៅសកម្មភាពក្នុងពេលខាងមុខរបស់វិទ្យាស្ថាន ដោយអនុលោមតាមក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។

❖ គណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន៥លើក៖

- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ប្រសិទ្ធភាព បញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តតាកែវ និងខេត្តព្រៃវែង។
- អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ប្រសិទ្ធភាព បញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ និងការអភិវឌ្ឍមូលដ្ឋាន ព្រមទាំងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។
- អញ្ជើញនាំយកអំណោយមនុស្សធម៌ ដែលរួមមាន ឱសថ បរិក្ខារពេទ្យ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ប្រគល់ជូនរដ្ឋបាលខេត្តសៀមរាប។
- អញ្ជើញនាំយកអនុស្សរណៈនៃការយោគយល់ស្តីពី ការផ្តល់អំណោយមនុស្សធម៌ដែលរួមមាន ឱសថ បរិក្ខារពេទ្យ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ប្រគល់ជូនរដ្ឋបាលខេត្តតាកែវ និងខេត្តកំពត និង
- អញ្ជើញនាំយកអំណោយមនុស្សធម៌របស់ព្រឹទ្ធសភា ប្រគល់ជូនរដ្ឋបាលខេត្តតាកែវ និងខេត្តកំពត។

## ៣-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារតំណាង៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភាបាន៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖**
  - អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារព័ត៌មានផ្សព្វផ្សាយរបស់សមាគមអតីតយុទ្ធជនកម្ពុជា (C.V.A) នៅវិមាន៧មករា និង
  - បន្តតាមដានដោយយកចិត្តទុកដាក់ខ្ពស់បំផុត និងផ្តល់ប្រឹក្សាយោបល់ជូនរាជរដ្ឋាភិបាលអំពីការវិវត្តសភាពការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។
- **សកម្មភាពចុះមូលដ្ឋាន៖** បានអញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន ចំនួន៥លើក រួមមាន៖
  - ការជួបប្រជុំជាមួយមេបញ្ជាការអង្គភាពចំណុះទិសទី២ និងទិសទី៣ នៅទីបញ្ជាការស្រាលទិសទី៣ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។
  - ការជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង នៅខេត្តឧត្តរមានជ័យ ចំនួន២៤៨នាក់។
  - ការជួបប្រជុំជាមួយមេបញ្ជាការអង្គភាព និងយោធិនប្រចាំទិសទី១ នៅបញ្ជាការដ្ឋានអង្គរក្សជួរមុខទិសទី១ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
  - ការជួបសំណេះសំណាល សួរសុខទុក្ខជនភៀសខ្លួន នៅទីទួលសុវត្ថិភាព នៅវត្តពោធិ៍ ៥០០០ដើម ខេត្តព្រះវិហារ និង
  - ការជួបសំណេះសំណាលជាមួយសមាជិក សមាជិកាក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ខេត្តព្រះវិហារ ចំនួន៤៦៤នាក់ នៅសាលាខេត្តព្រះវិហារ។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** អញ្ជើញចូលរួមក្នុងព្រះរាជពិធី និងជាអធិបតីក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៥២លើក។

❖ **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភាបាន៖**

- **សកម្មភាពដឹកនាំ និងចូលរួមកិច្ចប្រជុំ៖**
  - អញ្ជើញចូលរួមកិច្ចប្រជុំរួមរវាងតំណាងព្រឹទ្ធសភា ជាមួយក្រុមប្រឹក្សាធម្មនុញ្ញស្តីពីសេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅសាលប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ។
  - អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយក្រុមទីប្រឹក្សា ក្រុមជំនួយការខុទ្ទកាល័យ មន្ត្រីពិធីការ និងថ្នាក់ដឹកនាំអគ្គលេខាធិការ ចំនួន៥លើក ដើម្បីពិភាក្សាកិច្ចការទូទៅ និងត្រៀមចុះសួរសុខទុក្ខជនភៀសសឹក និងវីរកងទ័ព នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - អញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ចំនួន៤លើក ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅបន្ត និង
  - អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយគណៈកម្មការទាំង១០ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ដើម្បីពិនិត្យវឌ្ឍនភាព

ការងារ និងកំណត់ទិសដៅការងារបន្តរបស់ក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **សកម្មភាពចុះមូលដ្ឋាន៖**
  - អញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រមុខរដ្ឋស្តីទី និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា៖
    ១- ចុះសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ឱសថ និងសម្ភារប្រើប្រាស់ផ្សេងៗ ជូនប្រជាពលរដ្ឋ និងកុមារភៀសសឹក នៅក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ និងវីរយុទ្ធជនឈរជើង នៅតាមបណ្តោយព្រំដែន ចំនួន៧លើក និង
    ២- ចុះសួរសុខទុក្ខវីរយុទ្ធជនរងរបួស ដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យនានា នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។
  - អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ អាជ្ញាធរមូលដ្ឋាន ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និងផ្សព្វផ្សាយអំពីសភាពការណ៍ព្រំដែនកម្ពុជា ចំនួន៧លើក នៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកណ្តាល និងខេត្តព្រះវិហារ។
  - អញ្ជើញប្រគល់ផ្ទះចំនួន២ខ្នង និងសម្ភារប្រើប្រាស់ចាំបាច់ក្នុងផ្ទះជូនដល់ប្រជាពលរដ្ឋចំនួន២គ្រួសារ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ ព្រមទាំងសម្ភារប្រើប្រាស់ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសប្បុរសជននានា នៅខេត្តកំពង់ចាម។
  - ចាត់ទីប្រឹក្សា និងក្រុមការងារមន្ត្រីខុទ្ទកាល័យ អញ្ជើញចុះសាកសួរសុខទុក្ខ និងនាំយកអំណោយរបស់ ឯកឧត្តមអនុប្រធានទី១ និងសប្បុរសជន និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ ជូនវីរយុទ្ធជនការពារព្រំដែន ចំនួន២លើក នៅខេត្តឧត្តរមានជ័យ និង
  - ណែនាំ និងចាត់សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទីប្រឹក្សា និងមន្ត្រីខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ចំនួន៨លើក ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ និងសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ក្រុមហ៊ុន Laboratoire Bioderma សាធារណរដ្ឋបារាំង ពិនិត្យព្យាបាលជំងឺ ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ និងពិនិត្យការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធនានា នៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៥០លើក។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ្សនា អនុប្រធានទី២ព្រឹទ្ធសភាបាន៖**

- **សកម្មភាពដឹកនាំ និងចូលរួមកិច្ចប្រជុំ៖**
  - អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន១៦លើក។
  - អញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែ និងកំណត់ទិសដៅការងារបន្ត ជាមួយប្រធាន

គណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្ត និងការរៀបចំផែនការអាទិភាពការងារសម្រាប់ឆ្នាំ២០២៦ ចំនួន៩លើក នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- អញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីស្នើច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ចំនួន២លើក នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមកិច្ចប្រជុំដើម្បីពិនិត្យពិភាក្សាលើសេចក្ដីព្រាងច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាមួយគណៈកម្មការទី៦រដ្ឋសភា និងគណៈកម្មការទី៤រដ្ឋសភា នៅសាលសន្និសីទបាយ័ន វិមានរដ្ឋសភា និង
- អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយវិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កិច្ចការត្រូវធ្វើ រួមមាន៖ ការកែច្នៃអាហារ ការផលិតពូជដំណាំ និងផ្កា ការផលិតជី ការបង្កើតប្រព័ន្ធគ្រប់គ្រងឌីជីថល និងការរួមគ្នាបង្កើតផ្សារសម្រាប់ផលិតផលខ្មែរ ដោយមានការចូលរួមពីសាកលវិទ្យាល័យរដ្ឋ ចំនួន២០ វិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

▪ **សកម្មភាពចុះមូលដ្ឋាន៖**

- អញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចុះសួរសុខទុក្ខ និងចែកអំណោយជូនប្រជាពលរដ្ឋភៀសសឹក ចំនួន២លើក នៅខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។
- អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ អាជ្ញាធរមូលដ្ឋាន កងកម្លាំងឈរជើងជួរមុខ នៅតាមខ្សែបន្ទាត់ព្រំដែន ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ និងជាអធិបតីក្នុងពិធីផ្សេងៗ ចំនួន៨លើក នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ និងខេត្តព្រះវិហារ។
- ចាត់តំណាងប្រគល់សម្ភារមួយចំនួនដល់កងពលតូចអន្តរាគមន៍លេខ១ និងលេខ៩ ប្រចាំទិសមុំបី ប្រកតាថាវ ខេត្តព្រះវិហារ។
- ចាត់តំណាងប្រគល់អង្ករ ទឹកបរិសុទ្ធ និងសម្ភារមួយចំនួន ជូនដល់វីរកងទ័ពជួរមុខ ចំនួន២លើក។
- អញ្ជើញចុះពិនិត្យភូមិសាស្ត្រ និងស្ថានភាពភូមិជោគជ័យ និងភូមិព្រៃចាន់ នៅឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ។
- អញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចំនួន៣លើក នៅខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ។

- អញ្ជើញចុះទៅពិនិត្យស្រះចិញ្ចឹមត្រី និងការកែច្នៃត្រី ដើម្បីពិនិត្យលទ្ធភាពក្នុងការពង្រីក ទីផ្សារផ្គត់ផ្គង់បន្ថែម នៅខេត្តកំពង់ឆ្នាំង និង
- អញ្ជើញទស្សនកិច្ចសិក្សា នៅសិប្បកម្មផលិត និងកែច្នៃប្រហុក ផលិតផលរបស់កម្ពុជា (CONFIREL Prahok Manufacturing) ដោយមានការចូលរួមពីទីប្រឹក្សា ថ្នាក់ដឹកនាំ ខុទ្ទកាល័យ និងលោកគ្រូ អ្នកគ្រូ នៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប នៅខណ្ឌ ជ្រោយចង្វារ រាជធានីភ្នំពេញ។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖** អញ្ជើញជាអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការ ផ្សេងៗ ចំនួន៧៦លើក។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

▪ បានអញ្ជើញជាអធិបតី និងគណៈអធិបតី វេទិកា និងសិក្ខាសាលា ចំនួន១៧លើក ស្តីពី៖

១/ វឌ្ឍនភាពនៃការចុះបញ្ជីដីធ្លី-បរិយាកាសគ្មានវិវាទ។

២/ សេចក្តីប្រកាសនយោបាយក្រោយកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ ស្តីពី ជំងឺរបេង (UNHLM-TB) និងរបាយការណ៍ស្តីពី អភិបាលកិច្ចជំងឺរបេងឆ្នាំ២០២៤។

៣/ ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR) និងពិធីអបអរសាទរទិវាប្រាក់រៀល ខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ (២០ មីនា ១៩៨០- ២០ មីនា ២០២៥)។

៤/ អំពីសមិទ្ធផលការទូតសភារបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ ឆ្នាំ២០២៤។

៥/ បម្រែបម្រួលប្រជាសាស្ត្រ និងជំងឺមិនឆ្លង៖ គោលនយោបាយ ឆ្លើយតបបញ្ហាប្រឈម សម្រាប់ប្រជាជនសកម្ម និងយុវជន។

៦/ ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន។

៧/ ការឈ្វេងយល់អំពីក្របខណ្ឌយុទ្ធសាស្ត្រក្នុងការអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទ អន្តរជាតិស្តីពី ប្រជាជន និងការអភិវឌ្ឍ ICPD-PoA។

៨/ លទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កម្ពុជា និងសភាពការណ៍អន្តរជាតិ។

៩/ ការកំណត់លក្ខខណ្ឌនៃការប្រើប្រាស់ដី និងការគ្រប់គ្រងនគរូបនីយកម្ម និងសំណង់ ក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក។

១០/ សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា។

១១/ ភាពធន់នៃសេដ្ឋកិច្ច និងការជំនួសការនាំចូល។

១២/ ការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦។

១៣/ ការពង្រឹងសមត្ថភាពដឹកនាំក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី និងសហគ្រិនជាស្ត្រី រួមទាំង

វិស័យឌីជីថល។

១៤/ វឌ្ឍនភាព វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈការអនុវត្តយុទ្ធសាស្ត្រ បញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល។

១៥/ វេទិកាសាធារណៈ ដើម្បីស្តាប់សំណូមពរ និងកង្វល់នានារបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព។

១៦/ ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា និង

១៧/ ស្ត្រីក្នុងភាពជាអ្នកដឹកនាំរបស់ស្ត្រី និងក្មេងស្រី ដើម្បីទាំងអស់គ្នា។

- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធី ចំនួន៧លើក ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន៤៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន៣៩លើក រួមមាន៖

១/ ពិធីថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះបរមរតនកោដ្ឋ**។

២/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ចំនួន១ខ្នងនៃវិទ្យាល័យ ហេង សំរិន។

៣/ ពិធីសម្ពោធអគារសិក្សា ចំនួន១ខ្នង ជាអំណោយអង្គការសប្បុរសជនជប៉ុន។

៤/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារ និងសមិទ្ធផលនានា។

៥/ ពិធីសម្ពោធឆ្លងអគារសិក្សា និងសមិទ្ធផលនានាក្នុងវត្តព្រះឥន្ទសាមគ្គីធម៌។

៦/ ពិធីបញ្ចុះបឋមសិលាសាងសង់អគារ និងសមិទ្ធផលនានា។

៧/ ពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងឆ្លងសមិទ្ធផលនានាក្នុងវត្តកំចាយមារ។

៨/ ពិធីក្រុងពាលី និងចុះអនុស្សរណៈសាងសង់អគារសិក្សា១ខ្នង មានចំនួន៥បន្ទប់ ដែលជាអំណោយរបស់សមាគមមូលនិធិទូទៅ ដើម្បីសុខុមាលភាពជាតិ និងជួយគ្នាទៅវិញទៅមក។

៩/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ១០។

១០/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

១១/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦។

១២/ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី ប្រតិបត្តិការរវាងគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភាជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន។

១៣/ ពិធីប្រគល់-ទទួល សម្ភារវេជ្ជសាស្ត្រ ឱសថ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ

( Global Life Sharing ) ជូនរដ្ឋបាលខេត្តកណ្តាល ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។

១៤/ ពិធីប្រគល់ទទួលម៉ាស៊ីនលាងឈាម និងបរិក្ខារពេទ្យ ជូនដល់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

១៥/ ពិធីប្រគល់អំណោយមនុស្សធម៌របស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជូនរដ្ឋបាលខេត្តតាកែវ និងខេត្តកំពត ចំនួន២លើក។

១៦/ ពិធីបុណ្យវិសាខបូជា។

១៧/ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន។

១៨/ ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ ធ្នូ ២០២៥។

១៩/ ពិធីអនុស្សាវរីយ៍ខួបមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣៣។

២០/ ពិធីជួបសំណេះសំណាលរវាង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា ជាមួយគណៈប្រតិភូក្រសួង និងគណៈប្រតិភូក្រុមហ៊ុន ចំនួន៦ ក្នុងឱកាសខួបទី១៦២ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៥ និងខួបលើកទី៧០ឆ្នាំនៃកាកបាទក្រហមកម្ពុជា ក្រោមមូលបទ "រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ"។

២១/ ខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៥ ក្រោមប្រធានបទ " សិទ្ធិសមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប "។

២២/ ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាកំណើតរណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា។

២៣/ ពិធីមីទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៦ នៃទិវាជ័យជម្នះ ៧ មករា ១៩៧៩-៧ មករា ២០២៥។

២៤/ ពិធីសំណេះសំណាលជាមួយសិស្ស និស្សិត និងលោកគ្រូ អ្នកគ្រូ នៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល ជា ស៊ីម កំចាយមារ។

២៥/ ពិធីសំណេះសំណាលសួរសុខទុក្ខ និងចែកអំណោយមនុស្សធម៌ដល់សមាជិកមូលនិធិត្រីចក្រយានកម្ពុជា ចំនួន៣៨៦នាក់។

២៦/ ពិធីសំណេះសំណាលសួរសុខទុក្ខ និងចែកចង្រ្កានសន្សំសំចៃថាមពល សារុង និងថវិកា ជូនប្រជាពលរដ្ឋ ចំនួន៧០៦គ្រួសារ។

២៧/ ពិធីសំណេះសំណាលជាមួយសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍នៅទូទាំងប្រទេស។

២៨/ ពិធីចែកអំណោយដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយខ្យល់កន្ត្រាក់។

២៩/ ពិធីដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធចំពោះវីរយុទ្ធជន វីរយុទ្ធនារី និងប្រជាជនកម្ពុជា ក្នុងឱកាសរំលឹកខួបលើកទី៤៨នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យ

ពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧-២០ មិថុនា ២០២៥។

៣០/ ពិធីបុណ្យពុទ្ធាភិសេក និងឆ្លងសារមន្ទីរ ពិស្តារប្រាំពីរចប់ និងខួបគម្រប់១០ឆ្នាំ និងគម្រប់១៦ឆ្នាំ ជូន **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ ញ៉ែម សឿន ជាស៊ីម**។

៣១/ ពិធីទូងស្គរអបអរសាទរការដាក់បញ្ចូល "បូជនីយដ្ឋានចងចាំនៃកម្ពុជា៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា និងសន្តិភាព" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។

៣២/ ទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី៩ ឆ្នាំ២០២៥។

៣៣/ ពិធីប្រកាសជ័យលាភីឃុំ សង្កាត់ ដែលបានចូលរួមចលនាប្រឡងប្រណាំង "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" ក្នុងក្របខណ្ឌលក្ខណៈសម្បត្តិទី៦ ឆ្នាំ២០២៥ និងការផ្សព្វផ្សាយគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"។

៣៤/ ពិធីប្រកាសកាន់មុខតំណែងអភិបាលនៃគណៈអភិបាលខេត្តកោះកុង។

៣៥/ ចូលរួមពិធីកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌតាមប្រពៃណី និងគន្លងព្រះពុទ្ធសាសនា។

៣៦/ មហាសន្និបាតវិសាមញ្ញតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស។

៣៧/ ចេញផ្សាយរបាយការណ៍ស្តីពី ការតាមដានលើការអនុវត្តអនុសញ្ញាស៊ី-ដ សម្រាប់ឆ្នាំ ២០២៣ និង២០២៤ និង

៣៨/ ពិធីបើកនៃកម្មវិធីតាំងពិព័រណ៍ស្តីពី ទម្លាយភាពស្ងៀមស្ងាត់នៃអំពើហិង្សាផ្លូវភេទក្រោមរបបខ្មែរក្រហម។

- ក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខ និងពិភាក្សាការងារ ចំនួន៦១លើក ជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម សំណូមពរ ការអនុវត្តគោលនយោបាយនានា នាំយកអំណោយ និងចូលរួមដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ នៅតាមបណ្តាភូមិភាគទាំង៨។
- បានអញ្ជើញចូលរួមកិច្ចប្រជុំ ចំនួន២៣លើក រួមមាន៖

១/ ការគ្រប់គ្រង និងការអភិរក្សដីសមូហភាពរបស់ជនជាតិដើមភាគតិច និងបញ្ហាផ្សេងៗ។

២/ បូកសរុបលទ្ធផលការងារចន្លោះសម័យប្រជុំ និងការពង្រឹងគណនេយ្យភាពសមាជិកព្រឹទ្ធសភា ជាមួយអង្គបោះឆ្នោត ចំនួន២លើក។

៣/ ការកៀរគរឆន្ទៈនយោបាយក្នុងការអនុវត្តរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា។

៤/ រៀបចំទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៥ និងខួបលើកទី៧០ នៃកាកបាទក្រហមកម្ពុជា។

៥/ ប្រកាសសមាសភាពគណៈកម្មការរៀបចំគណៈប្រតិភូសភាកម្ពុជាចូលរួម AIPA Caucus លើកទី១៦ និងសមាសភាពសមាជិកសភាវ័យក្មេងអាយប៉ា (AIPA) ដែលត្រូវចូលរួមកម្មវិធី AIPA Roadshow។

៦/ ប្រជុំគណៈអចិន្ត្រៃយ៍សមាគមនារីកម្ពុជា ដើម្បីត្រួតពិនិត្យលើវឌ្ឍនភាពការងារគណៈកម្មការរៀបចំមហាសន្និបាតវិសាមញ្ញសមាគមនារី។
៧/ ការជូនព័ត៌មានអំពីការរៀបចំប្រជុំសមាជរបស់រដ្ឋសភា និងព្រឹទ្ធសភា លើកទី១។
៨/ ការត្រៀមរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីបញ្ញាសិប្បនិម្មិត (AI) និងអភិបាលកិច្ចឌីជីថល (Digital Governance) សម្រាប់ស្ថាប័នព្រឹទ្ធសភា។
៩/ ត្រៀមរៀបចំសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលស្តីពី ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលដោយផ្តោតលើការអនុវត្តគោលនយោបាយវិស័យអប់រំ យុវជន និងកីឡា។
១០/ ស្តីពី គំនិតផ្តួចផ្តើមរបស់ព្រឹទ្ធសភាចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមតាមព្រំដែន។
១១/ ត្រៀមរៀបចំសន្និបាតរបស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍។
១២/ ត្រៀមជួបពិភាក្សាការងារជាមួយ **ឯកឧត្តម TSUTSUMI Naohiro** ឯកអគ្គរដ្ឋទូតជប៉ុនទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស សន្តិភាព និងស្ថិរភាពអន្តរជាតិនៃក្រសួងការបរទេសជប៉ុន អំពីវឌ្ឍនភាពស្ថានភាពសិទ្ធិមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា។
១៣/ ក្រុមសមាជិកាព្រឹទ្ធសភា ពិនិត្យលើខ្លឹមសាររបាយការណ៍ចុះជួបសំណេះសំណាលឈ្វេងយល់ពីតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី នៅភូមិភាគទី៧។
១៤/ ក្រុមការងារផ្នែកឯកជន វេទិការាជរដ្ឋាភិបាល ផ្នែកឯកជន ដើម្បីពិគ្រោះយោបល់បន្ទាន់រកគ្រប់វិធីជួយសម្រួលដល់ការលំបាករបស់កសិករ ពាណិជ្ជករ អាជីវករ ទេសចរណ៍ និងការដឹកជញ្ជូន។
១៥/ ពិភាក្សាការងារជាមួយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
១៦/ ការពិនិត្យវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្តរបស់ក្រុមយន្តការនានារបស់ព្រឹទ្ធសភា។
១៧/ ផ្សព្វផ្សាយការងារចលនាសហជីព និងការងាររណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជារាជធានី។
១៨/ កិច្ចប្រជុំកំពូលព្រះពុទ្ធសាសនាបីប្រទេសកម្ពុជា-ឡាវ-វៀតណាម លើកទី៣។
១៩/ ការកំណត់ប្រធានបទសំខាន់ៗ ដើម្បីផ្សព្វផ្សាយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញមាត្រា៣៣ និងផ្សព្វផ្សាយសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។
២០/ បូកសរុបលទ្ធផលការងារចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥។
២១/ ត្រៀមរៀបចំប្រជុំតាមប្រព័ន្ធនិម្មិត (Online) លើការងារប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកល។

២២/ ប្រជុំផ្ទៃក្នុងអំពីការស្រាវជ្រាវអំពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងសេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

- បានអញ្ជើញជាវាគ្មិន ក្នុងកម្មវិធីបាឋកថា បទបង្ហាញ ចំនួន៧លើក ស្តីពី៖
  - ១/ រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ចំនួន៣លើក។
  - ២/ ការស្រាវជ្រាវ អង្កេត និងវិភាគរបស់សមាគមសហគ្រិនស្ត្រីកម្ពុជាពាក់ព័ន្ធនឹងស្ត្រី។
  - ៣/ សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន។
  - ៤/ គោលនយោបាយការបរទេស និងវិស័យការទូតសភា និង
  - ៥/ ការផ្លាស់ប្តូរពីការធ្វើកសិកម្មបែបប្រពៃណី ទៅជាកសិកម្មកែច្នៃតាមបែបទំនើប។
- បានអញ្ជើញទទួលជួបប្រជាពលរដ្ឋមកពី ខេត្តពោធិ៍សាត់ ខេត្តសៀមរាប និងលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស មកពីសាលា Milky Way ចំនួន៣០២នាក់ អញ្ជើញមកសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម និងកសិ-ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន ទំនប់ទឹក និងចំការដំណាំហូបផ្លែច្រើនប្រភេទ នៅខេត្តកំពង់ស្ពឺ។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ចំនួន១៦លើក នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។
- បានអញ្ជើញទទួលជំនួយមនុស្សធម៌លើកទី១៣ និងលើកទី១៤ របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ រួមមាន ឧបករណ៍វេជ្ជសាស្ត្រ ឱសថ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃផ្សេងៗ នៅវិមានព្រឹទ្ធសភា។
- បានអញ្ជើញជួបពិភាក្សាការងារជាមួយសមាគមពេទ្យព្យាបាលដោយចលនា(សពចក) ដឹកនាំដោយ **លោក ហៀម ហឿង** ប្រធាន និង**ឯកឧត្តម សុខ សំណាង** ប្រធានកិត្តិយសនៃសមាគម នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយជួយឧបត្ថម្ភជូនប្រជាពលរដ្ឋភៀសសឹក បងប្អូនវីរកងទ័ពជួរមុខការពារព្រំដែន នៅរាជធានី និងតាមបណ្តាខេត្តនានា ចំនួន១,៣១៤លើក ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ ចំនួន១,៥៧២លើក។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន២២លើក។
- បានអញ្ជើញអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង ប្រចាំការក្នុងស្ថានការណ៍នៃការប្រយុទ្ធប្រឆាំងទប់ទល់នឹងការឈ្លានពានប្រដាប់អាវុធ របស់យោធាថៃមកលើដែនអធិបតេយ្យរបស់ព្រះរាជាណាចក្រកម្ពុជា។
- បានអញ្ជើញនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារផ្សេងៗ និងថវិកា សម្រាប់ ប្រគល់ជូនវីរកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹក នៅវិមាន៧មករា។
- បានអញ្ជើញប្រគល់អំណោយជូន **លោក ស៊ូ សារ៉ាង** នាយកប្រតិបត្តិនៃសមាគមចលនា វប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ នៅវិមានព្រឹទ្ធសភា។
- បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីវ័យចំណាស់ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរទិវាមនុស្សចាស់កម្ពុជា និងទិវា មនុស្សចាស់អន្តរជាតិលើកទី២៧ ១តុលា ឆ្នាំ២០២៥ ក្រោមប្រធានបទ "វ័យចាស់ដោយ សេចក្តីថ្លៃថ្នូរ" នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា និង
- បានអញ្ជើញជាអធិបតី ចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ នៅរាជធានី ភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៩១លើក។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងប្រគល់អំណោយឧបត្ថម្ភរបស់ **សម្តេចអគ្គមហាសេនា បតីតេជោ ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ និងជាប្រធានព្រឹទ្ធសភា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជូនកងទ័ពជួរមុខ នៅកងពលធំអន្តរាគមន៍លេខ២ និងបានជួបសម្តែងការគួរសមជាមួយ **ឯកឧត្តមនាយឧត្តម សេនីយ៍កិត្តិសង្គហបណ្ឌិត ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និង ជាមេបញ្ជាការកងអង្គរក្ស ព្រមទាំងបានជួបសំណេះសំណាលជាមួយកងកម្លាំងឈរជើង នៅ ប្រាសាទតាមន្ត ខេត្តឧត្តរមានជ័យ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីទូងស្គរអបអរសាទរការដាក់បញ្ចូល "បូជនីយដ្ឋានចងចាំនៃកម្ពុជា៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា និងសន្តិភាព" ក្នុងបញ្ជី បេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈិត សុខុន** ប្រធានគណៈកម្មការទី៧ ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញទទួលជួបតំណាងធនាគារអេស៊ីលីដា ក្នុងឱកាសទទួលថវិកាវិភាគទានរបស់ធនាគារអេស៊ីលីដា ចំនួន២០០លានរៀល សម្រាប់មូលនិធិព្រឹទ្ធសភា សម្រាប់គាំទ្រកងទ័ពជួរមុខ និងជនភៀសសឹក (ព.ស.ក.ទ និង ជ.ភ.ស) នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា **ឯកឧត្តម អោក ប៉ូរ៉ា** និង **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីប្រកាសចូលកាន់តំណែង **ឯកឧត្តម ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជូនក្រុមគ្រួសារសព **ឯកឧត្តម មួង ប៉យ** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ព្រមទាំងបានចូលរួមរៀបចំចាត់ចែងពិធីបុណ្យសពតាមប្រពៃណីជាតិនៅគេហដ្ឋាននៃសព ស្ថិតនៅក្រុងបានលុង ខេត្តរតនគិរី។
- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន១៦លើក។
  - បានអញ្ជើញដឹកនាំ ចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន១៥២លើក។
- **ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៧លើក។
  - តំណាង **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកបច្ច័យចំនួន២,០០០,០០០រៀល ប្រគេនព្រះចៅអធិការវត្តបុទុមគង្គា ក្នុងឱកាសបុណ្យកឋិនទាននៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
  - បានអញ្ជើញដឹកនាំ ចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន១០៩លើក។
- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញចូលរួមអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាននៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៣លើក។
  - បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌កម្ពុជា(AMH)

របស់សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ចំនួន៨លើក ព្រមទាំងបានប្រគល់រទេះរុញ ចំនួន ២គ្រឿង និង

- បានអញ្ជើញចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា ចំនួន៧៩លើក។

❖ សមាជិក សមាជិកាសហភាពសហព័ន្ធយុវជនកម្ពុជា នៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានៈ

- អញ្ជើញបរិច្ចាគឈាមមនុស្សធម៌ តាមការអំពាវនាវរបស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្ដេចតេជោ (TYDA) នៅមជ្ឈមណ្ឌលមហាសន្និបាតកោះពេជ្រ។
- អញ្ជើញចូលរួមបរិច្ចាគឈាម ក្រោមប្រធានបទ "យើងរួមគ្នាបរិច្ចាគឈាម ១,០០០សាក់ ដើម្បីសង្គ្រោះជីវិត" នៅមជ្ឈមណ្ឌលកីឡាកងយោធពលខេមរភូមិន្ទ និង
- អញ្ជើញនាំយកស្បៀងអាហារ និងសម្ភារប្រើប្រាស់ជូនដល់ប្រជាពលរដ្ឋភៀសសឹក ចំនួន ៣៧៩គ្រួសារ នៅខេត្តព្រះវិហារ។

- បានរៀបចំកម្មវិធីបទបង្ហាញស្ដីពី "បទពិសោធន៍នៃការអនុវត្តគោលនយោបាយរបស់សាធារណរដ្ឋប្រជាមានិតចិន" និង"ការចែករំលែកបទពិសោធន៍ និងការអនុវត្តអភិបាលកិច្ចរបស់សាធារណរដ្ឋប្រជាមានិតចិន"។
- បានរៀបចំទទួលដំណើរទស្សនកិច្ច និងធ្វើបទបង្ហាញស្ដីពី "រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសាវតារបស់ព្រឹទ្ធសភា" ប្រគេនព្រះសង្ឃ និងជូនសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត និងសិស្សានុសិស្សមកពីសាលា សមាគម វិទ្យាស្ថាន និងសាកលវិទ្យាល័យនានា ចំនួន១០លើក មានសិក្ខាកាម ចំនួន៧៤៤អង្គ/នាក់។
- បានប្រគល់ថវិកាឧបត្ថម្ភរបស់ព្រឹទ្ធសភា និងឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភា ជូនកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបលើកទី១៦២ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៥ និងខួបលើកទី៧០ឆ្នាំនៃកាកបាទក្រហមកម្ពុជា។
- បាននាំយកថវិកា និងអំណោយមួយចំនួនរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៤៧ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ២ ធ្នូ ១៩៧៨ - ២ ធ្នូ ២០២៥។
- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃ ចំនួន១៦០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា បុណ្យវិសាខបូជា និងអំណោយ ចំនួន៦០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។
- បានសហការរៀបចំកម្មវិធីដាក់ឱ្យប្រើប្រាស់បណ្ណាល័យមេគង្គ-ឡានឆាង នៅសាលាបឋមសិក្សាព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានរៀបចំតុបតែងលម្អសង្ក្រាន្ត ការសម្ដែងរបាំត្រុដិ ព្រមទាំងបានរៀបចំពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងវណ្ដាប់ទទួលទេវតាឆ្នាំថ្មី នៅវិមានព្រឹទ្ធសភា ក៏ដូចជាអាហារសាមគ្គី ក្នុងឱកាស

អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩។

- បានរៀបចំសែនដង្វាយក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និង
- បានទទួលពាក្យបណ្តឹង ចំនួន៩៣បណ្តឹង បញ្ជូនពាក្យបណ្តឹងទៅក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ចំនួន៣បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង និងស្ថាប័នពាក់ព័ន្ធ ចំនួន២៧បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន២បណ្តឹង បញ្ជូនពាក្យបណ្តឹងទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៧៧បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន១១៩បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៧៥បណ្តឹង ធ្វើលិខិតរំលឹកជំរុញការដោះស្រាយ ចំនួន១៦បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន១៨បណ្តឹង បានទទួលលិខិតថ្លែងអំណរគុណពីម្ចាស់បណ្តឹងគោរពជូន សម្តេចតេជោប្រធានព្រឹទ្ធសភា តាមរយៈគណៈកម្មការ ចំនួន២បណ្តឹង និងធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន សម្តេចតេជោប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន២៤បណ្តឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **ការទទួលសារតាំង៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា បានទទួលសារតាំង ចំនួន៣លើក នៅវិមានព្រឹទ្ធសភា រួមមាន៖
  - ១/ **ឯកឧត្តម** Tull TRAISORAT ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រថៃ ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ២/ **ឯកឧត្តម** Daouda Bitie ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតបួគីណាហ្វាសូ ប្រចាំព្រះរាជាណាចក្រកម្ពុជា និង
  - ៣/ **លោកជំទាវ** Vivian Loss Sanmartin ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសហព័ន្ធប្រេស៊ីល ប្រចាំព្រះរាជាណាចក្រកម្ពុជា។
- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ និងអង្គទូតនានាចូលជួបសម្តែងការគួរសម សំណេះសំណាល និងពិភាក្សាការងារ ចំនួន៦៥លើក រួមមាន៖
  - ជំនួបជាមួយភ្ញៀវជាតិ អន្តរជាតិ ចំនួន៤៩លើក រួមមាន៖
    - ១- សមាជិកព្រឹទ្ធសភាមកពីគណបក្សឆន្ទៈខ្មែរ ចំនួន៣រូប។
    - ២- ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។
    - ៣- ប្រធានក្រុមប្រឹក្សាភិបាលសម្ព័ន្ធសមាគមមូលនិធិសម្តេចតេជោ។
    - ៤- ប្រធានគណៈកម្មាធិការសាខាបក្សប្រចាំរដ្ឋអូរីហ្គិន និងក្រុមការងារ។
    - ៥- ប្រធានរដ្ឋសភានៃសហព័ន្ធម៉ាឡេស៊ី។
    - ៦- ប្រធានសភានៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត។
    - ៧- ប្រធានរដ្ឋសភាជាតិនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។

៨- អតីតប្រធានរដ្ឋសភានៃសាធារណរដ្ឋកូរ៉េ និងជាប្រធានក្រុមប្រឹក្សាអង្គការដើម្បីពិភពលោកទាំងអស់គ្នា (Global Together)។
៩- អនុប្រធានទី១នៃសភាជាតិហុងគ្រី។
១០- សមាជិកសភាជប៉ុន និងជាអតីតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុន។
១១- សមាជិករដ្ឋសភា និងជាទីប្រឹក្សាពិសេសនាយករដ្ឋមន្ត្រីជប៉ុន។
១២- សមាជិកព្រឹទ្ធសភាសហព័ន្ធម៉ាឡេស៊ី។
១៣- សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាអនុប្រធានគណៈកម្មាធិការកិច្ចការជនជាតិភាគតិចនៃសភាតំណាងប្រជាជនចិន។
១៤- សមាជិកការិយាល័យនយោបាយ និងជាលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន។
១៥- ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន។
១៦- ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន។
១៧- ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី (តាមប្រព័ន្ធទូរស័ព្ទ)។
១៨- នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ។
១៩- នាយករដ្ឋមន្ត្រីកុំមិនវែលដូមីនីកា។
២០- នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសិង្ហបុរី។
២១- ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍តំបន់ និងជនបទនៃសហព័ន្ធម៉ាឡេស៊ី។
២២- ឧបនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
២៣- រដ្ឋមន្ត្រីពាណិជ្ជកម្មនៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន។
២៤- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សិល្បៈ និងវប្បធម៌នៃសហព័ន្ធម៉ាឡេស៊ី។
២៥- អនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសវៀតណាម និងជាអគ្គសេនាធិការនៃកងទ័ពប្រជាជនវៀតណាម។
២៦- អនុរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌា។
២៧- អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម (តាមប្រព័ន្ធនិម្មិត)។
២៨- អគ្គលេខាធិការអន្តរសភាអាស៊ាន (AIPA)។
២៩- អគ្គលេខាធិការនៃសន្និសីទប្រធានសភានៃអន្តរសភា(ISC)។
៣០- អគ្គរដ្ឋអាជ្ញានៃសហព័ន្ធរុស្ស៊ី។
៣១- មេបញ្ជាការកងស្វ័យការពារជើងគោកជប៉ុន។
៣២- មេបញ្ជាការកងទ័ពជើងគោកនៃសាធារណរដ្ឋហ្វីលីពីន។
៣៣- មេបញ្ជាការកងយោធពលភូមិន្ទនៃប្រទេសប្រ៊ុយណេ។
៣៤- រដ្ឋទាយាទនៃបូរីក្សត្រលុចសំបួ។

៣៥- គណៈប្រតិភូកុងស៊ុលកិត្តិយសអឺរ៉ុបនៃសាធារណរដ្ឋស៊ីប (Cyprus)។
៣៦- ប្រធានគណបក្សសហភាពសាមគ្គី និងអភិវឌ្ឍន៍មីយ៉ាន់ម៉ា (USDP)។
៣៧- អនុប្រធានប្រតិបត្តិសាលាបក្សនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន (CCPS) និងជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិនអាណត្តិទី២០។
៣៨- ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)។
៣៩- ប្រធានវិទ្យាស្ថានយុទ្ធសាស្ត្រ KSI ប្រចាំតំបន់អាស៊ី ប៉ាស៊ីហ្វិក។
៤០- ប្រធានសមាគមជប៉ុន-កម្ពុជា និងគណៈប្រតិភូជំរុញការវិនិយោគជប៉ុន។
៤១- ប្រធានផ្នែកទំនាក់ទំនង និងជាទីប្រឹក្សាពិសេសនៃ Sheikh Mansour bin Jabor AI Thani នៃក្រុមហ៊ុន AI Mansour Asia នៃប្រទេសកាតា។
៤២- ប្រធាន និងជានាយកប្រតិបត្តិក្រុមហ៊ុន Minebea Mitsumi Inc. នៃប្រទេសជប៉ុន។
៤៣- អគ្គនាយក និងជានាយកប្រតិបត្តិ (CEO) ក្រុមហ៊ុន Japan Tobacco International (JTI) សកលលោក។
៤៤- គណៈប្រតិភូវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់កិច្ចការអាស៊ាន និងអាស៊ីបូព៌ា (ERIA)។
៤៥- នាយកប្រតិបត្តិសាជីវកម្មទេសចរណ៍ជប៉ុន។
៤៦- ស្ថាបនិកអង្គការសម្ព័ន្ធយុវជនអន្តរជាតិ International Youth Fellowship (IYF)។
៤៧- តំណាងអង្គការយូណេស្កូ ប្រចាំព្រះរាជាណាចក្រកម្ពុជា។
៤៨- សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី និងជាស្ថាបនិកក្រុមហ៊ុន Mayapada Group និង
៤៩- **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត Sir Konstantin (Kostya) S. Novoselov FRS** អ្នកទទួលពានរង្វាន់ណូបែលរូបវិទ្យា។

- ជំនួបឯកអគ្គរដ្ឋ/រាជទូតវិសាមញ្ញ និងពេញសមត្ថភាព ប្រចាំព្រះរាជាណាចក្រកម្ពុជា ចំនួន១៦លើក រួមមាន៖
  ១- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរី។
  ២- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា។
  ៣- ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី។
  ៤- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
  ៥- ភារធារីស្តីទីស្ថានទូតសហរដ្ឋអាមេរិក។
  ៦- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ចំនួន២លើក។
  ៧- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង ចំនួន២លើក។

៨- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក ចំនួន២លើក។
៩- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ។
១០- ឯកអគ្គរដ្ឋទូតកាណាដា។
១១- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស។
១២- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋអូទ្រីស និង
១៣- ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់។

- **សកម្មភាពការងារនៅក្រៅប្រទេស៖**
    - បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ចំនួន៥លើក រួមមាន៖
        ១- អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា បំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
        ២- អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមកិច្ចប្រជុំកំពូលបក្សទ្វេភាគី កម្ពុជា-វៀតណាម និងត្រីភាគី កម្ពុជា-ឡាវ-វៀតណាម នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម។
        ៣- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមខួបអនុស្សាវរីយ៍លើកទី៥០ នៃទិវាជ័យជម្នះភាគខាងត្បូង និងទិវាបង្រួបបង្រួមជាតិវៀតណាម នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម។
        ៤- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា បំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង
        ៥- អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ទៅបំពេញទស្សនកិច្ច និងចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិវៀតណាម (២ កញ្ញា ១៩៤៥ - ២ កញ្ញា ២០២៥) នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា៖

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** បានអញ្ជើញដឹកនាំកិច្ចប្រជុំការងារ ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (APF) ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ និងឯកអគ្គរដ្ឋទូតនៃបណ្តាប្រទេសនានា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន១៦លើក រួមមាន៖
    ១- ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨។
    ២- ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា។
    ៣- ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសប្រធានក្រុមមេធាវីរាជរដ្ឋាភិបាល និងជា

ប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្ដេចតេជោសែន។

៤- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

៥- គណៈប្រតិភូអូស្ត្រាលីដឹកនាំដោយ **លោកជំទាវ** Fiona Phillips សមាជិកសភា និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន។

៦- គណៈប្រតិភូសមាគមនិស្សិតកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន (ACSC)។

៧- សមាជិករដ្ឋសភាតួកគីយេ។

៨- ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី។

៩- ភារធារីស្ដីទីនៃស្ថានទូតសហរដ្ឋអាមេរិក។

១០- សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ចនៃសភាប្រឹក្សានយោបាយប្រជាជនចិន។

១១- គណៈប្រតិភូគណៈកម្មាធិការសម្រាប់ភាពជាអ្នកជិតខាងល្អ មិត្តភាព និងកិច្ចសហប្រតិបត្តិការនៃអង្គការសហប្រតិបត្តិការសៀងហៃ (GNFCC)។

១២- ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ។

១៣- នាយកប្រតិបត្តិសមាគមចិន និងគណៈកម្មការសេដ្ឋកិច្ចពាណិជ្ជកម្មអាស៊ីបាស៊ីហ្វិក។

១៤- សមាគមនិស្សិតប្រចាំសាធារណរដ្ឋប្រជាមានិតចិន CUGB។

១៥- គណៈប្រតិភូសមាគមនិស្សិតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន និង

១៦- តំណាងក្រុមហ៊ុន Laboratoire Bioderma និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសាធារណរដ្ឋបារាំង។

- **សកម្មភាពការងារក្រៅប្រទេស៖**
  - បានអញ្ជើញបំពេញការងារនៅក្រៅប្រទេស ចំនួន១០លើក រួមមាន៖

១- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងបានបន្តអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង (APF) នៅខេត្តកាន់ថឺនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

២- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធក្រោមមូលបទ "សកម្មភាពសភាដើម្បីការអភិវឌ្ឍសង្គម និងយុត្តិធម៌" នៅទីក្រុងតាស្គិននៃសាធារណរដ្ឋអ៊ូសបេគីស្ថាន។

៣- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមមហាសន្និបាត លើកទី១៥១ នៃសហភាពអន្តរសភា (IPU-151) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

៤- អញ្ជើញចូលរួមអម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បំពេញទស្សនកិច្ចការងារនៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងទស្សនកិច្ច

ផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។

៥- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលរួមវេទិកាលើកទី៣ នៃកិច្ចសន្ទនាសភាត្បូង-ត្បូង ( South-South Parliamentary Dialogue ) ក្រោមប្រធានបទ កិច្ចសន្ទនាអន្តរតំបន់ និងទ្វីប នៅបណ្តាប្រទេសភាគខាងត្បូង ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ និងដើម្បីសម្រេចឱ្យបាននូវសន្តិភាព សន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍរួម នៅព្រះរាជាណាចក្រម៉ារ៉ុក។

៦- អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភានៃព្រះរាជាណាចក្រកម្ពុជា ចូលរួមសម័យប្រជុំប្រចាំឆ្នាំលើកទី៥០នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង។

៧- អញ្ជើញចូលរួមពិធីបើកផ្លូវការនៃសម័យប្រជុំប្រចាំឆ្នាំសភាប្រើភាសាបារាំង លើកទី៥០ ក្រោមអធិបតីភាព **ឯកឧត្តម Gérard LARCHER** ប្រធានព្រឹទ្ធសភាបារាំង។

៨- អញ្ជើញថ្លែងបទអន្តរាគមន៍ទៅកាន់ប្រធាន សមាជិក និងសមាជិកានៃសភាប្រើភាសាបារាំងប្រមាណ៥៥០នាក់ ដោយសង្កត់ធ្ងន់ទៅលើបញ្ហាប្រទេសថៃរំលោភដែនអធិបតេយ្យកម្ពុជា និងមិនគោរពចំពោះយុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិ ( ICJ )។

៩- អញ្ជើញចូលរួមសន្និសីទគ្រឿងបរិក្ខារសមុទ្រពិភពលោកឆ្នាំ២០២៥ ក្រោមមូលបទ "នាំក្តីសុបិន្តរបស់មនុស្សជាតិឆ្ពោះទៅកាន់អនាគតថ្មី" នៅទីក្រុងហ្វូចូវ ខេត្តហ្វូចៀន សាធារណរដ្ឋប្រជាមានិតចិន និង

១០-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាចូលរួម "សន្និសីទសាមគ្គីភាពសង្គមស៊ីវិលអន្តរជាតិ លើកទី២ស្តីពី គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល" នៅទីក្រុងហូហាត តំបន់ស្វយ័តម៉ុងហ្គោលី សាធារណរដ្ឋប្រជាមានិតចិន។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញជាអធិបតីក្នុងពិធីពិសាអាហារការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិ ចំនួន៧លើក។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទឡ្ហនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ និងអន្តរជាតិ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន២៣លើក រួមមាន៖

១- គណៈប្រតិភូព្រឹទ្ធសភាដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា។

២- ក្រុមប្រឹក្សាអភិវឌ្ឍន៍ និងស្តារកសិកម្មនៅកម្ពុជា។

៣- តំណាងក្រុមហ៊ុន Metfone។

៤- ប្រធានវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ( CDRI )។

៥- គណៈប្រតិភូសមាគមកាហ្វេកម្ពុជា (Cambodia Coffee Association)។
៦- ស្ថាប័នហិរញ្ញវត្ថុ (ARDB, AMRET, AMK, CAMMA) សមាគមកាហ្វេកម្ពុជា និងក្រុមហ៊ុន Limsa Development Group។
៧- សមាគមកាហ្វេកម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ក្រុមហ៊ុន នីលីដា និង អង្គការ CAPRED។
៨- វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប និងក្រុមហ៊ុនស្អាត។
៩- តំណាងនាយកប្រតិបត្តិសាលាអន្តរជាតិផារ៉ាហ្គន និងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន។
១០- ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី។
១១- ឯកអគ្គរដ្ឋទូតសហព័ន្ធម៉ាឡេស៊ី។
១២- ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប។
១៣- ឯកអគ្គរដ្ឋទូតជប៉ុន និងអ្នកជំនាញនយោបាយអន្តរជាតិ។
១៤- ឯកអគ្គរដ្ឋទូតទទួលបន្ទុកសិទ្ធិមនុស្ស សន្តិភាព និងស្ថិរភាពអន្តរជាតិនៃក្រសួងការបរទេសជប៉ុន។
១៥- ប្រធានមូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍ។
១៦- ប្រធានក្រុមហ៊ុន និងសមាគម Chuna Yu របស់សាធារណរដ្ឋប្រជាមានិតចិន។
១៧- ក្រុមហ៊ុនវិនិយោគជប៉ុន។
១៨- អភិបាលក្រុង Kota ប្រទេសជប៉ុន។
១៩- អតីតនិស្សិតមកពីសាកលវិទ្យាល័យ Nagoya ប្រទេសជប៉ុន។
២០- គណៈប្រតិភូកូរ៉េ នៃវិទ្យាស្ថានបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ (DIST)។
២១- **សាស្ត្រាចារ្យ Hyun-Hoon Lee** ប្រធាន THE 4TH WAY INSTITUTE និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យជាតិ Kangwon សាធារណរដ្ឋកូរ៉េ ។
២២- អគ្គនាយកផ្នែកទីផ្សារនៃក្រុមហ៊ុន SuRaLa Net និង
២៣- **លោកស្រីបណ្ឌិត វិទ្ធី ឌី អាឌីពូទ្រី** ដែលកំពុងធ្វើការស្រាវជ្រាវ នៅសាកលវិទ្យាល័យ Jyvaskyla នៅសាធារណរដ្ឋហ្វាំងឡង់។

- **បេសកកម្មក្រៅប្រទេស៖** បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ចូលរួមវេទិកាវប្បធម៌សុខដុមនីយកម្មពិភពលោក ឆ្នាំ២០២៥ (2025 Hehe Culture Global Forum) នៅទីក្រុងថាយចូវ ខេត្តហ្សឺជាំងនៃសាធារណរដ្ឋប្រជាមានិតចិន និង
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញជាអធិបតីក្នុងពិធីពិសាអាហារការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិ ចំនួន៤លើក។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមកិច្ចប្រជុំ មហាសន្និបាត សន្និសីទ វេទិកា សិក្ខាសាលា និងទស្សនកិច្ចការងារនៅក្រៅប្រទេស ចំនួន៤៦លើក រួមមាន៖

១/ កិច្ចប្រជុំត្រៀមរៀបចំមហាសន្និបាតលើកទី១១ តំបន់អាស៊ី-ប៉ាស៊ីហ្វិកនៃសភាប្រើភាសាបារាំង តាមប្រព័ន្ធនិម្មិត នៅសាលប្រជុំពិសេសកណ្ដាល វិមានព្រឹទ្ធសភា។
២/ កិច្ចប្រជុំត្រៀមរៀបចំការប្រជុំប្រចាំឆ្នាំរបស់ក្រុមអ្នកនយោបាយអាយប៉ា(AIPA) លើកទី១៦ នៅវិមានរដ្ឋសភា។
៣/ កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងសេចក្ដីសម្រេចទាំង១៦ ដែលគណៈកម្មាធិការរៀបចំនឹងត្រូវលើកយកមកពិភាក្សាមហាសន្និបាតអាយប៉ាលើកទី៤៦ នៅប្រទេសម៉ាឡេស៊ី នៅសាលប្រជុំគណៈកម្មការទី៥។
៤/ កិច្ចប្រជុំត្រៀមការងារមួយចំនួន ដើម្បីទៅចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៦ នៅវិមានរដ្ឋសភា។
៥/ កិច្ចប្រជុំផ្ទៃក្នុងរបស់សភាសមាជិកអាយប៉ា មុននឹងចូលរួមកិច្ចប្រជុំរួមគ្នារវាងថ្នាក់ដឹកនាំអាយប៉ា និងប្រមុខដឹកនាំអាស៊ាន ដើម្បីពិភាក្សាលើសេចក្ដីព្រាងសាររបស់អាយប៉ា ដែលឆ្លុះបញ្ចាំងលើប្រធានបទបរិយាបន្ន និងនិរន្តរភាពនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៦ នៅវិមានរដ្ឋសភានៃសហព័ន្ធម៉ាឡេស៊ី។
៦/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំបន់អាស៊ី(APA)ស្ដីពី សេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។
៧/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំបន់អាស៊ី(APA)ស្ដីពី កិច្ចការនយោបាយ នៅទីក្រុងបាកដាដ សាធារណរដ្ឋអ៊ីរ៉ាក់។
៨/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំបន់អាស៊ី(APA)ស្ដីពី កិច្ចការនយោបាយ នៅទីក្រុងម៉ាសាដ សាធារណរដ្ឋឥស្លាមអ៊ីរ៉ង់។
៩/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំបន់អាស៊ី(APA)ស្ដីពី កិច្ចការសង្គម និងវប្បធម៌ នៅទីក្រុងមូស្គូ សហព័ន្ធរុស្ស៊ី។
១០/ កិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាត លើកទី១៥ នៃសភាតំបន់អាស៊ី (APA) នៅទីក្រុងបាគូ សាធារណរដ្ឋអាស៊ែបៃហ្សង់។
១១/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង(APF) នៅខេត្តកាន់ថឺ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
១២/ កិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើភាសាបារាំង(APF) នៅទីក្រុងវៀងចន្ទន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
១៣/ កិច្ចប្រជុំអនុគណៈកម្មការបណ្ដាញសមាជិកសភាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត ចំនួន២លើក នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
១៤/ កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងតាមដាននៅក្នុងគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង(APF) នៅសាធារណរដ្ឋសេណេហ្គាល់។
១៥/ កិច្ចប្រជុំត្រៀមរៀបចំប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង

ឆ្នាំ២០២៦ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

១៦/ កិច្ចប្រជុំត្រៀមរៀបចំប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នៅសាលភក្តីវិក្រម២ វិមានព្រឹទ្ធសភា។

១៧/ កិច្ចប្រជុំប្រចាំឆ្នាំលើកទី៥០នៃសភាប្រើភាសាបារាំង (APF) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង។

១៨/ កិច្ចប្រជុំស្តីពី "សហគ្រិនភាពរបស់ស្ត្រីហ្វ្រង់កូហ្វូន" នៃគណៈកម្មការកិច្ចការសេដ្ឋកិច្ច សង្គម និងបរិស្ថាននៃសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នៅសាលប្រជុំព្រះវិហារវិមានរដ្ឋសភា។

១៩/ កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិចលនាសេរីនិយមអន្តរជាតិ (Liberal International) លើកទី២០៩ នៅទីក្រុងឡាអេ ប្រទេសហូឡង់។

២០/ កិច្ចប្រជុំសភាលើកទី៣០នៃសន្និសីទភាគីក្របខណ្ឌអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ នៅទីក្រុង Belém សាធារណរដ្ឋសហព័ន្ធប្រេស៊ីល។

២១/ កិច្ចប្រជុំចង្អៀតត្រៀមរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ឆ្នាំ២០២៦ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

២២/ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៃបណ្តាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រុមសីលធម៌ សមាជិកសភា ដើម្បីពិភាក្សាកម្មវិធី និងប្រធានបទសម្រាប់មហាសន្និបាតប្រចាំឆ្នាំ តាមប្រព័ន្ធនិម្មិត នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

២៣/ កិច្ចប្រជុំពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជាស្តីពី "កិច្ចការទូទៅពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរសភារវាងប្រទេសទាំងពីរ" នៅសាលប្រជុំគណៈកម្មការទី៥ វិមានព្រឹទ្ធសភា។

២៤/ កិច្ចប្រជុំផ្សព្វផ្សាយ តម្រង់ទិសដល់និស្សិតអាហារូបករណ៍មូលនិធិមុទិតា និងចែករំលែកបទពិសោធន៍អំពីការត្រៀមខ្លួនទៅសិក្សាបន្ត នៅសាធារណរដ្ឋប្រជាមានិតចិន។

២៥/ មហាសន្និបាតពិភពលោកឆ្នាំ២០២៥ នៃសហព័ន្ធសន្តិភាពពិភពលោក៖ ការបង្កើតយុគសម័យថ្មីនៃសន្តិភាព និងវិបុលភាព នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ។

២៦/ មហាសន្និបាតសហភាពអន្តរសភាលើកទី១៥១ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ សហព័ន្ធស្វីស។

២៧/ មហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៦ (AIPA-46th) ដឹកនាំដោយ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅសហព័ន្ធម៉ាឡេស៊ី។

២៨/ មហាសន្និបាតលើកទី១៥ និងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិលើកទី៥១ នៃក្រុមប្រឹក្សាសេរីនិយម និងប្រជាធិបតេយ្យអាស៊ី នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ។

២៩/ មហាសន្និបាតគណៈមេធាវីនៃសាធារណរដ្ឋបារាំង និងធ្វើបទបង្ហាញសង្ខេបស្តីពីច្បាប់សាធារណរដ្ឋបារាំង និងក្រមរដ្ឋប្បវេណីរបស់កម្ពុជា នៅសាធារណរដ្ឋបារាំង។

៣០/ សន្និសីទអន្តរជាតិរៀបចំដោយក្រុមប្រឹក្សាសេរីនិយម និងប្រជាធិបតេយ្យអាស៊ី (CALD) នៅមហាវិទ្យាល័យ Miriam ទីក្រុង Quezon សាធារណរដ្ឋហ្វីលីពីន។
៣១/ សន្និសីទសមាជិកសភាស្តីពី ការអប់រំសម្រាប់ជីវិត សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស នៅទីក្រុងតូក្យូ ព្រះរាជាណាចក្រជប៉ុន។
៣២/ សន្និសីទក្រោមមូលបទ "រួមគ្នាដើម្បីភាពធន់អាកាសធាតុ" នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។
៣៣/ សិក្ខាសាលាសហប្រតិបត្តិការអន្តរសភាថ្នាក់តំបន់ស្តីពី គោលនយោបាយអាកាសធាតុ នៅព្រះរាជាណាចក្រថៃ។
៣៤/ សិក្ខាសាលាថ្នាក់តំបន់ស្តីពី "ការបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវពីថវិកាអាកាសធាតុ និងប្រសិទ្ធភាពនៃតួនាទីរបស់សភា ក្នុងការតាមដាន និងត្រួតពិនិត្យហិរញ្ញវត្ថុអាកាសធាតុនៅអាស៊ាន" (តាមប្រព័ន្ធនិម្មិត) នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
៣៥/ សិក្ខាសាលាអន្តរជាតិក្រោមប្រធានបទ "ទស្សនវិស័យក្នុងតំបន់ស្តីពី ព័ត៌មានមិនពិត និងឥទ្ធិពលរបស់វា" នៅទីក្រុងព្រុចសែល ព្រះរាជាណាចក្របែលហ្ស៊ិក។
៣៦/ សិក្ខាសាលាស្តីពី "កិច្ចសន្ទនាសភា៖ ការផ្សារភ្ជាប់ទំនាក់ទំនងសភារវាងសហភាពអឺរ៉ុប និងកម្ពុជា (Parliamentary Dialogue : EU-Cambodia Parliamentary Network)" ចំនួន២លើក នៅសាលសន្និសីទបន្ទាយស្រី វិមានរដ្ឋសភា។
៣៧/ សិក្ខាសាលាស្តីពី ការចូលរួមរបស់ប្រជាពលរដ្ឋ និងសភាបើកចំហរសម្រាប់អភិបាលកិច្ចប្រកបដោយបរិយាបន្ន នៅទីក្រុងវៀងចន្ទន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
៣៨/ សិក្ខាសាលាស្តីពី ការផ្លាស់ប្តូរការអនុវត្តជាក់ស្តែងលើប្រធានបទស្តីពី សញ្ញាណនៃផលប្រយោជន៍ផ្ទាល់ខ្លួន តាមប្រព័ន្ធនិម្មិត នៅសាលភក្តីវិក្រម២ វិមានព្រឹទ្ធសភា។
៣៩/ វេទិកាកិច្ចសហប្រតិបត្តិការច្បាប់ចិន-អាស៊ាន លើកទី៧ នៅទីក្រុងឆុងឈីង សាធារណរដ្ឋប្រជាមានិតចិន។
៤០/ វេទិកាសន្តិភាព ទីក្រុងប៉ារីសស្តីពី "សម្ព័ន្ធភាពថ្មី ដើម្បីសន្តិភាព ប្រជាជន និងភពផែនដី" នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង។
៤១/ ទស្សនកិច្ចសិក្សា នៅរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
៤២/ ទស្សនកិច្ចការងារនៅអគ្គលេខាធិការដ្ឋានអាយប៉ា នៅទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូណេស៊ី។
៤៣/ ការទទួលស្វាគមន៍ **លោក គីម ជុងណាម** (Kim Jung-Nam) ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ អញ្ជើញបំពេញទស្សនកិច្ចការងារ នៅព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង
៤៤/ ទទួលបដិសណ្ឋារកិច្ចស្វាគមន៍គណៈប្រតិភូសភាប្រឹក្សានយោបាយប្រជាជនចិន

ដឹកនាំដោយ **ឯកឧត្តម វ៉ាង គួសឹង** (Wang Guosheng) សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងជាប្រធានគណៈកម្មាធិការទទួលបន្ទុកកិច្ចការសេដ្ឋកិច្ចនៃសភាប្រឹក្សានយោបាយប្រជាជនចិន CPPCC នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។

- បានអញ្ជើញជួបសវនាការ ពិភាក្សាការងារ និងសម្តែងការគួរសម ជាមួយភ្ញៀវជាតិ និងអន្តរជាតិនានា ចំនួន២៨លើក រួមមាន៖

១/ **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដើម្បីសហការរៀបចំកម្មវិធីប្រគំតន្ត្រីសប្បុរសធម៌កម្ពុជា-កូរ៉េ។

២/ **លោក ហ្វូជី តូរូ** ប្រធានសភាក្រុងកូតា និងអ្នកវិនិយោគទុន ជនជាតិជប៉ុន ចំនួន៧នាក់។

៣/ **ឯកឧត្តម គីម ប្យុងជោ** (Kim byung-Joo) សមាជិករដ្ឋសភានៃសាធារណរដ្ឋកូរ៉េ។

៤/ **ឯកឧត្តម Nikoloz Samkharadze** សមាជិកសភា និងជាប្រធានគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិនៃសភាប្រទេសហ្សកហ្ស៊ី។

៥/ **លោក ប្រេត ហ័រតុន** (Brett Horton) គណៈប្រតិភូសមាជិកខុទ្ទកាល័យសមាជិកសភាអាមេរិក។

៦/ **ឯកឧត្តម ដារេក យីប** (Derek Yip) ឯកអគ្គរដ្ឋទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា។

៧/ **លោកស្រី អេនជេឡា កូរកូរេន** (Angela Corcoran) ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំសាធារណរដ្ឋនៃសហភាពមីយ៉ាន់ម៉ា។

៨/ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** (UENO Atsushi) ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

៩/ **ឯកឧត្តម TSUTSUMI Naohiro** ឯកអគ្គរដ្ឋទូតជប៉ុន ទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស សន្តិភាព និងស្ថេរភាពអន្តរជាតិ ប្រចាំព្រះរាជាណាចក្រកម្ពុជា។

១០/ **លោកស្រី កូហ្គា អាស៊ីកា** លេខាទី៣ស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

១១/ ឯកឧត្តម **Dominic Williams** ឯកអគ្គរាជទូតអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា។

១២/ **លោកជំទាវ មីលេណា ការីដាដ ហ្សាលឌីវើ ភីដ្រា** (Milena Caridad Zaldivar Pirdra) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា។

១៣/ **ឯកឧត្តម Antoine RIPOLL** អគ្គទីប្រឹក្សាផ្នែកទំនាក់ទំនងជាមួយសភាតំបន់អាស៊ីអាគ្នេយ៍ និងជាតំណាងស្ថានទូតសហភាពអឺរ៉ុបប្រចាំតំបន់អាស៊ាន។

១៤/ **លោកឧកញ៉ា ឌិន សុមេធារិទ្ធ** ប្រធានសហព័ន្ធទេសចរណ៍កម្ពុជា និង**លោក Jean Paul Vogels**។

១៥/ **ឯកឧត្តម ឡូរ៉េន វើលី** (Laurent Wehrli) ប្រធានគណៈកម្មាធិការគោលនយោបាយការបរទេសនៃក្រុមប្រឹក្សាជាតិនៃសហព័ន្ធស្វីស។

១៦/ **កញ្ញា សារ៉ា វីលសាវ៉** ប្រធានពាណិជ្ជកម្មកាណាដា។

១៧/ **ឯកឧត្តម យ៉ុងចាង មីន** តំណាងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ។

១៨/ **លោក លី ជិន យូក** អគ្គនាយកក្រុមហ៊ុន Cropmate Fertilizer Sdn.Bhd ដែលជាក្រុមហ៊ុនផលិតជីពាក់កណ្ដាលសរីរាង្គ និងជីគីមី។

១៩/ **លោក វ៉ាង ហ្សី ហេង** អគ្គនាយកក្រុមហ៊ុន DIMENG GROUP។

២០/ **លោក ខៀវ កូឡា** អគ្គនាយករងទទួលបន្ទុកព័ត៌មាននៃទូរទស្សន៍ CNC។

២១/ **លោកស្រី អ៊ីស៊ូកូ អ៊ីសេគី** គណៈប្រតិភូក្រុមហ៊ុនជប៉ុន Nakanishi Kosan។

២២/ **លោក ភីធូ ឡាញ់ លោកស្រី ស៊ីសារ៉ា ទ្រីផាមស៊ាប** (Sisira Trepermsub) និង **លោកស្រី បេនច្រេសស៊ីរី វឌ្ឍនាប៉ានុម** (Benchasiri Wattanapanom) តំណាងក្រុមហ៊ុន Price Waterhouse Coopers។

២៣/ ក្រុមអ្នកវិនិយោគទុនមកពីសាធារណរដ្ឋសង្គមនិយមវៀតណាម នៅខេត្តកំពង់ស្ពឺ។

២៤/ ក្រុមការងារនៃនាយកដ្ឋានអភិវឌ្ឍន៍វិទ្យាស្ថានលេខ២ របស់ក្រុមហ៊ុន DIST នៃសាធារណរដ្ឋកូរ៉េ ដើម្បីស្វែងរកដៃគូអភិវឌ្ឍន៍ទាក់ទងនឹងវិស័យកសិកម្មកម្មវិធី (Smart Farm)។

២៥/ ក្រុមហ៊ុនជប៉ុន **FOREX SENDAI** តាមប្រព័ន្ធវីដេអូ ដើម្បីសិក្សាលទ្ធភាពវិនិយោគបង្កើតរោងចក្រផលិតជីកំប៉ុស ជីសរីរាង្គប្រកបដោយគុណភាពខ្ពស់ និងតម្លៃសមរម្យ។

២៦/ ក្រុមហ៊ុនជប៉ុន **FUJIURA LTD** ដើម្បីសិក្សាអំពីឱកាសវិនិយោគចំណុចសក្ដានុពលធំៗរបស់កម្ពុជា។

២៧/ ក្រុមអ្នកវិនិយោគជនជាតិជប៉ុន និង

២៨/ ក្រុមអ្នកវិនិយោគជប៉ុន-ចិន។

- បានអញ្ជើញចូលរួមពិធីផ្លូវការផ្សេងៗ ចំនួន១៥លើក៖

  ១/ កម្មវិធីខួបលើកទី៧៥នៃការបង្កើតទំនាក់ទំនងទ្វេភាគីរវាងសហរដ្ឋអាមេរិក និងព្រះរាជាណាចក្រកម្ពុជា នៅសារមន្ទីរជាតិកម្ពុជា រាជធានីភ្នំពេញ។

  ២/ កម្មវិធីខួបលើកទី៦ របស់វិទ្យាស្ថានចក្ខុវិស័យអាស៊ី ក្រោមប្រធានបទ "គោលនយោបាយការបរទេសកម្ពុជាក្នុងយុគសម័យថ្មី" និងកម្មវិធីពិសេសស្ដីពី ការដាក់សម្ពោធសៀវភៅ "អាស៊ាន និងទំនួលខុសត្រូវក្នុងការការពារ ASEAN and Responsibility to Protect (R2P)៖ ទំនាក់ទំនងដែលមានភាពស្រពិចស្រពិល" នៅសណ្ឋាគារហៃយ៉ាត់រីជិនស៊ី រាជធានីភ្នំពេញ។

  ៣/ ពិធីបុណ្យឯករាជ្យជាតិខួបលើកទី២៤៩ នៃសហរដ្ឋអាមេរិក រៀបចំដោយស្ថានទូតសហរដ្ឋអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។

៤/ ពិធីខួបលើកទី៦០ ទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសិង្ហបុរី នៅសណ្ឋាគារ រាហ្វហ្វលល៍ ឡឺរ៉ូយ៉ាល់ រាជធានីភ្នំពេញ។

៥/ ពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០ នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។

៦/ ពិធីអបអរសាទរខួបលើកទី៧១ នៃការបង្កើតកងកម្លាំងស្វ័យការពាររបស់ជប៉ុន នៅស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

៧/ សន្និសីទប្រធានសភាពិភពលោកលើកទី៦ និងកិច្ចប្រជុំកំពូលលើកទី១៥ នៃប្រធានសភាជាស្ត្រី នៅទីក្រុងហ្សឺណែវ សហព័ន្ធស្វីស។

៨/ ពិធីបើក និងពិធីបិទកិច្ចប្រជុំក្រុមអ្នកនយោបាយអាយប៉ា (AIPA Caucus) លើកទី១៦ ស្ដីពី "សន្តិភាពតាមរយៈការសន្ទនា៖ មាគ៌ាឆ្ពោះទៅមុខរបស់សភា" នៅអគាររដ្ឋបាល វិមានរដ្ឋសភា។

៩/ កម្មវិធីសមាជអេកូឡូស៊ីអន្តរជាតិនេវស្គីលើកទី១១ Programme of the Eleventh Nevsky Ecological Congress តាមប្រព័ន្ធនិម្មិតពីទីក្រុង Saint Petersburg សហព័ន្ធរុស្ស៊ី ក្រោមប្រធានបទ "អេកូឡូស៊ីនៃតថភាពថ្មី៖ បញ្ហាប្រឈម និងឱកាស" នៅសាលពិសេសកណ្តាល វិមានព្រឹទ្ធសភា។

១០/ ពិធីសម្តែងក្បាច់រាំអន្តរជាតិរបស់និស្សិតសាកលវិទ្យាល័យ BYU (Brigham Young University) សហរដ្ឋអាមេរិក នៅសាលមហាស្រពពិព័រណ៍កោះពេជ្រ។

១១/ ពិធីជួបជុំអតីតនិស្សិតយោធាកម្ពុជា-អូស្ត្រាលី ឆ្នាំ២០២៥ នៅ Raffles Hotel Le Royal រាជធានីភ្នំពេញ។

១២/ ការតាំងពិព័រណ៍រូបថតក្រោមប្រធានបទ "Tokyo Before/After" នៅសារមន្ទីរព្រះស្រីឦសានវរ្ម័ន។

១៣/ កម្មវិធី Gala ដើម្បីផ្តល់អាហារូបករណ៍ ដល់យុវជនខ្មែរក្រីក្រសម្រាប់ការសិក្សាចាប់ពីថ្នាក់បឋមសិក្សារហូតដល់បរិញ្ញាបត្រ នៅ Raffles Hotel Le Royal។

១៤/ កម្មវិធីអបអរសាទរការចូលជាសមាជិកទី១១ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ រាជធានីភ្នំពេញ និង

១៥/ កម្មវិធីអបអរសាទររបស់ **ឯកឧត្តមបណ្ឌិត ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ ព្រឹទ្ធសភា ទទួលគ្រឿងឥស្សរិយយស Grand Cross of Merit with Star of the Order of Merit of the Federal Republic of Germany របស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ពី ឯកឧត្តមប្រធានាធិបតី **បណ្ឌិត Frank Walter Steinmeier** នៅនិវេសនដ្ឋានឯកឧត្តមឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ រាជធានីភ្នំពេញ។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ចំនួន៥លើក រួមមាន៖ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋឥណ្ឌូណេស៊ី និងសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងពិធីជូនសារតាំង ជំនួបសម្តែងការគួរសម សំណេះសំណាល ពិភាក្សាការងារ និងក្នុងពិធីផ្សេងៗជាមួយភ្ញៀវអន្តរជាតិនានា ចំនួន៥៧លើក។
- បានអញ្ជើញចូលរួមអមដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ចូលរួមមហាសន្និបាតលើកទី១៥១ នៃសហភាពអន្តរសភា (IPU-151st) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ សហព័ន្ធស្វីស។
- បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងពិធីពិសាអាហារពេលព្រឹកការងារជាមួយ **លោកជំទាវ** Bridgette L.Walker ភារធារីស្តីទីនៃស្ថានទូតអាមេរិក ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញទៅបំពេញទស្សនកិច្ច និងចូលរួមកិច្ចប្រជុំ នៅក្រៅប្រទេស ចំនួន៣លើក រួមមាន៖ សហព័ន្ធស្វីស សាធារណរដ្ឋបារាំង និងសាធារណរដ្ឋប្រជាមានិតចិន។
- បានអញ្ជើញចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ នៃការបង្កើតកងស្វ័យការពារជប៉ុន នៅនិវេសនដ្ឋានឯកឧត្តមអគ្គរដ្ឋទូតជប៉ុន រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងពិធីបុណ្យជាតិសិង្ហបុរី លើកទី៦០ នៅសណ្ឋាគារ Raffles Le Royal។
- បានអញ្ជើញចូលរួមអបអរសាទរខួបលើកទី៧៩ នៃថ្ងៃឯករាជ្យជាតិឥណ្ឌា នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។
- បានអញ្ជើញចូលរួមកម្មវិធីអបអរសាទរការចូលជាសមាជិកទី១១ របស់អាស៊ាននៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅសណ្ឋាគារហៃយ៉ាត់រីជិនស៊ីភ្នំពេញ។
- បានអញ្ជើញចូលរួមកម្មវិធីបំពាក់គ្រឿងឥស្សរិយយសជាន់ខ្ពស់លំដាប់ទី២ របស់រាជរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដោយ ឯកឧត្តមអគ្គរដ្ឋទូតអាល្លឺម៉ង់ បំពាក់ជូន **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា នៅនិវេសនដ្ឋានឯកឧត្តមអគ្គរដ្ឋទូត និង
- បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ចំនួន៩លើក នៅបន្ទប់ឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។

- ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញពិនិត្យទីកន្លែងត្រៀមរៀបចំទទួលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវមកកាន់ព្រះរាជាណាចក្រកម្ពុជា។
- ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **ឯកឧត្តមបណ្ឌិត ជន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមនាយឧត្តមសេនីយ៍ ខាំតៃ ស៊ីផាន់ដន** អតីតនាយករដ្ឋមន្ត្រី និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
- ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - ▪ បានអញ្ជើញចូលរួមក្នុងជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងក្នុងកម្មវិធីផ្សេងៗ ជាមួយថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ចំនួន៥លើក។
  - ▪ បានអញ្ជើញចូលរួមរៀបចំពិធីបដិសណ្ឋារកិច្ចស្វាគមន៍ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ ក្នុងឱកាសទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា និងបានចូលរួមពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ រៀបចំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** ជូនឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅវិមានសន្តិភាព និង
  - ▪ បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមបណ្ឌិត ម៉ាន់ម៉ូហាន់ សិញ** អតីតនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋឥណ្ឌា នៅស្ថានទូតឥណ្ឌា រាជធានីភ្នំពេញ។
- ❖ បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ស្ថាតទូតឥណ្ឌា មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលសភាអាស៊ី(PCAsia) មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់កម្ពុជា មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន (CALRC) សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា(CADT) បណ្ណាល័យ និងបណ្ណសារដ្ឋានជាតិ-អន្តរជាតិ ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេស សាកលវិទ្យាល័យនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាអនុប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា ព្រមទាំងក្រុមការងារបច្ចេកទេសសាងសង់អគារថ្មីនៃព្រឹទ្ធសភា

បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា ជាប្រចាំ។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានអញ្ជើញជាគណៈអធិបតីក្នុងពិធីក្រុងពាលីបើកការដ្ឋានសាងសង់គម្រោងប្រព័ន្ធរំដោះទឹកក្នុងបរិវេណព្រឹទ្ធសភា។
- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
  - បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមការងារដឹកនាំដោយ **ឯកឧត្តម អ៊ឹម សុខរិទ្ធី** ទីប្រឹក្សាបច្ចេកទេសនៃក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម និងវប្បធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបន្តពិភាក្សារៀបចំចងក្រងសៀវភៅ "ប្រវត្តិស្ថាបត្យកម្មអគារនៅវិមានព្រឹទ្ធសភា ចាប់តាំងពីការបង្កើតនៅទសវត្សទី៦០ រហូតដល់ព្រឹទ្ធសភា នីតិកាលទី៥" នៅបន្ទប់ឯកឧត្តមអគ្គលេខាធិការ។
  - បានអញ្ជើញចុះពិនិត្យមើលស្ថានភាពអគារ និងបរិវេណអគារក្រហម ដែលទាមទារឱ្យមានការជួសជុលដំបូលអគារ កម្រាលថ្មម៉ាប និងបេតុងកន្លែងមួយចំនួនមានបញ្ហាជ្រាបទឹក និងប្រេះបែក។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំ ចំនួន២៤លើក ស្តីពី៖
    - ការកែទម្រង់របបសោធនសាធារណៈ។
    - ការអនុវត្តប្រាក់សោធននិវត្តន៍សម្រាប់បុគ្គលនៃវិស័យសាធារណៈ។
    - រៀបចំសេចក្តីសម្រេចអំពីការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
    - ក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
    - ក្រុមការងារវាយតម្លៃដំឡើងថ្នាក់មន្ត្រីរាជការ។
    - ពិនិត្យសម្រេចលើការប្រសិទ្ធនាមឈ្មោះបន្ទប់នៃអគារព្រឹទ្ធសភាថ្មី ដែលកំពុងសាងសង់។
    - ត្រៀមរៀបចំពិធីក្រុងពាលី និងពិធីចម្រើនព្រះបរិត្ត ជាពិសេសត្រៀមលក្ខណៈរៀបចំព្រះរាជពិធីសម្ពោធអគារព្រឹទ្ធសភាថ្មី "វិមានសាមគ្គីភាព"។
    - ត្រួតពិនិត្យបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា។
    - ក្រុមការងារស្រាវជ្រាវ និងវិភាគព្រឹត្តិការណ៍តំបន់ និងអន្តរជាតិនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
    - ការរៀបចំសិក្ខាសាលាស្តីពី បញ្ញាសិប្បនិម្មិត (AI) និងកិច្ចការពាក់ព័ន្ធផ្សេងៗ។
    - កិច្ចប្រជុំផ្ទៃក្នុងជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និង
    - បូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងទិសដៅការងារខែមករា ឆ្នាំ២០២៦ ចំនួន១២លើក។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញដឹកនាំកិច្ចដំណើរការពិនិត្យ និងរៀបចំបែបបទវាយតម្លៃសមត្ថភាពបុគ្គលិកជាប់កិច្ចសន្យា និងបន្តកិច្ចសន្យាការងារដល់បុគ្គលិកជាប់កិច្ចសន្យា នៅគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលពិសេសកណ្តាល វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញចុះពិនិត្យមើលការរៀបចំបណ្ណាល័យព្រឹទ្ធសភាថ្មី ដែលស្ថិតនៅជាន់ខាងក្រោមនៃអគារព្រឹទ្ធសភាថ្មី។
- **ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា៖
  - បានអញ្ជើញដឹកនាំក្រុមការងាររៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា ប្រជុំត្រួតពិនិត្យ និងធ្វើកំណត់ហេតុលើបញ្ជីសម្ភារ គ្រឿងសង្ហារិម ដែលនឹងត្រូវជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា ឆ្នាំ២០២៥ នៅសាលពិសេស វិមានព្រឹទ្ធសភា។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរស្ថាប័នស្តីពី ការកែទម្រង់របបសោធនសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
  - បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើ "សេចក្តីព្រាងអនុក្រឹត្យស្តីពី ការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មថ្នាក់ជាតិ" នៅសណ្ឋាគារសុខាភ្នំពេញ។
- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥ និងទិសដៅការងារខែមករា ឆ្នាំ២០២៦ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា ចំនួន១២លើក។

## ៥.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានរៀបចំរបាយការណ៍ឧបសម្ព័ន្ធនៃរបាយការណ៍អនុវត្តចំណូល-ចំណាយថវិកាជាតិរបស់ព្រឹទ្ធសភាប្រចាំឆ្នាំ២០២៤។
- បានធ្វើរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភា ប្រចាំឆមាសទី១ ឆ្នាំ២០២៥ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។
- បានរៀបចំគម្រោងផែនការថវិកាឆ្នាំ២០២៦ និងផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (ឆ្នាំ២០២៦-២០២៨)របស់ព្រឹទ្ធសភា រួចរាល់។
- បានបោះពុម្ពផ្សាយអាណត្តិសម្រាប់ត្រីមាសទី១ ទី២ ទី៣ និងទី៤ ជំពូក៦០ ៦១ ៦២ និង៦៤ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានផ្សាយអាណត្តិថ្លៃប្រើប្រាស់ទឹក អគ្គិសនី និងអ៊ីនធឺណែត បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានធ្វើកម្មវិធីចំណាយត្រីមាសទី១ ទី២ ទី៣ និងទី៤ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានធ្វើនិយ័តកម្មវិធីចំណាយជំពូក៦៤ ឆ្នាំ២០២៥ និងចុះប្រព័ន្ធ FMIS។
- បានស្នើសុំ និងទូទាត់ថវិកាបុរេប្រទាន ចំនួន១២បុរេប្រទាន សម្រាប់គណៈប្រតិភូជាន់ខ្ពស់ និង

គណៈប្រតិភូព្រឹទ្ធសភា បំពេញបេសកកម្ម និងទស្សនកិច្ចផ្លូវការនៅក្រៅប្រទេស ព្រមទាំងការទិញរថយន្តជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។

- បានស្នើសុំបុរេប្រទានថវិកា និងឥណទានថវិកាបន្ថែម ចំនួន១០បុរេប្រទាន សម្រាប់ចំណាយរៀបចំបុណ្យសពជូនសមាជិកព្រឹទ្ធសភា ចំនួន២រូប និងបេសកកម្មក្រៅប្រទេសរបស់ប្រតិភូព្រឹទ្ធសភា ព្រមទាំងទិញសម្ភារបំពាក់អគារថ្មីនៃព្រឹទ្ធសភា។
- បានស្នើសុំឥណទានបន្ថែមលើអនុគណនី (៦៤០៥៤) សម្រាប់ចំណាយបើកផ្តល់ជូននិវត្តជនជាសមាជិក សមាជិកាព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៥ និងអនុគណនី (៦៤០១៦) សម្រាប់ចំណាយបើកផ្តល់ជូនទីប្រឹក្សា នាយក នាយករង ជំនួយការ និងសមាជិក សមាជិកាខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាឆ្នាំ២០២៥។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ប្រាក់ឧបត្ថម្ភបុណ្យភ្ជុំបិណ្ឌ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជនមន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥។
- បានបង់ប្រាក់សំណៃសចំណាយប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥ ទៅធនាគារជាតិនៃកម្ពុជា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៩៥៨សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១,២២៥សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៧៣សំណើ។
- បានថតចម្លងឯកសារ ចំនួន៤១,០១៧ច្បាប់ និងចងក្រងធ្វើជាសៀវភៅ ចំនួន៥១ក្បាល ប្រើប្រាស់ក្រដាសអស់ ចំនួន៤៤៩,២៥២សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន៩៤៦លើក ស្មើនឹង៣,៤៥៩នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៣២៩លើក។

- បានទទួលលិខិតចូល ចំនួន៧,៦២១ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន៦,២៧៨ច្បាប់។
- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤១៨ច្បាប់ ស្មើនឹង១,៨៤៧នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន១០៩ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព មានជំងឺ គ្រោះថ្នាក់ចរាចរណ៍ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន៧២នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមានៈ
    - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន២០៤លើក។
    - បានតាំងលម្អដើមសុភមង្គលថ្មីក្នុងសាលជំនួបភ្ញៀវនៅអគារក្រហម តាំងលម្អផ្កាស្បៃរឿងក្រោមព្រះឆាយាល័ក្ខណ៍ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសព្រះរាជពិធីបុណ្យជាតិ។
    - បានតាំងលម្អដើមសុភមង្គល ផ្ការកាំមាស ផ្កាមិថុនា ផ្កាអ័រគីដេ ផ្កាផាវ ព្រមទាំងបានដាំដើមជ្រៃ ដើមឫស្សី ដើមប្រាំង ដើមម្លូពណ៌ និងដើមផ្លីសេ ចំនួន៤៩០គុម្ព/ផើង។
    - បានដាំស្មៅម៉ាឡេស៊ី នៅសួនច្បារក្នុងបរិវេណព្រឹទ្ធសភា។
    - បានរៀបចំក្រាលគ្រាប់គ្រួសក្នុងស៊ុមផ្កា នៅសួនច្បារសាលប្រជុំពេញអង្គ។
    - បានកែលម្អសួនច្បារនៅមុខអគារក្រហមជុំវិញដងទង់ជាតិ សួនច្បារជុំវិញរទេះគោ និងនៅមុខអគារក្រហម ដោយបានដាំផ្កា ចំនួន៩០៥គុម្ព។
    - បានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីដកដើមឈើនៅច្រកចូល P1 ជាប់អគារសាងសង់ថ្មី របស់ព្រឹទ្ធសភា។
    - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា ចំនួន២៤លើក។
    - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានទាក់ទងជាមួយសាកលវិទ្យាល័យជាតិបាត់ដំបង ដើម្បីបណ្តុះផ្កាកេសរកូលខ្មែរ ចំនួន៥០ពូជជូនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ប្រចាំឆ្នាំ២០២៥ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាៈ
    - មន្ត្រីរាជការក្របខណ្ឌ ចំនួន៧២០នាក់ (ស្រី២៩១) ក្នុងនោះមន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់, មន្ត្រីរាជការស្ថិតនៅក្រៅក្របខណ្ឌដើម ចំនួន៥នាក់, មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៣នាក់ និង
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៩២នាក់ (ស្រី៣៦នាក់)។
- បានពិនិត្យសេចក្តីព្រាង និងសេចក្តីសម្រេចស្តីពី គោលការណ៍នៃការបើកផ្តល់ និងទទួលថវិកា

របស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

- បានធ្វើសេចក្តីសម្រេច ចំនួន៦០ច្បាប់ និងលិខិតបង្គាប់ការ ចំនួន២២ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្គង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៧២ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមករា-ខែធ្នូ ប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៥ ចំនួន១៤លើក។
- បានសហការជាមួយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ រៀបចំធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំធ្វើបច្ចុប្បន្នភាពប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ជូនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ចំនួន៧៧៤ប័ណ្ណ។
- បានរៀបចំធ្វើបច្ចុប្បន្នភាពព័ត៌មានជីវប្រវត្តិមន្ត្រីរាជការក្របខណ្ឌនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើបច្ចុប្បន្នភាព និងព្រាងនូវកម្រងសំណួរសម្រាប់សិក្សាពីតម្រូវការជំនាញ តាម Google Form ដើម្បីត្រៀមធ្វើផែនការបណ្តុះបណ្តាលឆ្នាំ២០២៦។
- បានផ្សព្វផ្សាយរបាយការណ៍វាយតម្លៃសារពើភ័ណ្ឌជំនាញ និងតម្រូវការបណ្តុះបណ្តាលឆ្នាំ២០២៥ និងបញ្ជីវគ្គបណ្តុះបណ្តាលជូនគ្រប់នាយកដ្ឋាន អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានសម្របសម្រួល និងរៀបចំការផ្តល់អាហារូបករណ៍ ចំនួន៤៧កន្លែង របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សាកលវិទ្យាល័យជាតិគ្រប់គ្រង, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, សាកលវិទ្យាល័យអាស៊ីអឺរ៉ុប, សាកលវិទ្យាល័យវ៉ាន់ដា និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំវគ្គបណ្តុះបណ្តាលក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន៦វគ្គ មានសិក្ខាកាម ចំនួន១៥០នាក់។
- បានសម្របសម្រួលជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា នៅក្រៅស្ថាប័នព្រឹទ្ធសភា ចំនួន២៩វគ្គ មានសិក្ខាកាម ចំនួន១០៨នាក់។
- បានសហការ និងសម្របសម្រួលជូនមន្ត្រីរាជការ ចំនួន២៤រូប ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា នៅក្រៅប្រទេស ចំនួន៨វគ្គ នៅសាធារណរដ្ឋកូរ៉េ សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសម៉ាឡេស៊ី។
- ការងារសាងសង់សំណង់ថ្មីៗជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានរៀបចំទីកន្លែងសម្រាប់បំពេញការងារជូនអគ្គលេខាធិការរងព្រឹទ្ធសភា, ក្រុមការងារព័ត៌មាន, ទីប្រឹក្សា, មេបញ្ជាការអង្គរក្សការពារព្រឹទ្ធសភា, អគ្គនាយករងពិធីការ និង

ទំនាក់ទំនងអន្តរជាតិ និងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួន៧កន្លែង។

- បានជួសជុលផ្លាស់ប្តូរ គាស់ការ៉ូបាត និងរៀបការ៉ូថ្មីឡើងវិញ នៅតាមបន្ទប់ការិយាល័យសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣បន្ទប់។
- បានប្តូរហ្វុងអក្សរ( Background ) ឈ្មោះគណៈកម្មការ, ធ្វើ Logo សមាជវេទ្ធសភា នៅអគារក្រហម បន្ទប់ប្រជុំគណៈកម្មការទី១ ទី៤ ព្រមទាំងបានដំឡើងផ្ទាំងរូបភាពក្នុងកម្មវិធី **សម្តេចតេជោ** ជួបភ្ញៀវអន្តរជាតិ ចំនួន២១ផ្ទាំង/លើក។
- បានជួសជុលកែលម្អផ្នែកខាងលើដំបូលឃ្លាំង និងបានប្តូរ ជួសជុល ខាត់ លាប សំយ៉ាប ពិដាន ដំបូល ជញ្ជាំងក្នុង-ក្រៅ បង្កាន់ដៃឈើ បន្ទប់ទឹកជនពិការ Coffee Counter ដំបូលជ័រ ប៉ូលីកាប៉ោន ទទឹក បាញ់ការជញ្ជាំងកញ្ចក់ បិទការដំបូលស័ង្កសី អ៊ុតកៅស៊ូការពារជ្រាបទឹក បិទស្កុតការពារជ្រាបទឹកដំបូលអក្សរ VVV នៅតាមអគារ និងតាមសាលប្រជុំនានា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៤គ្រឿង/កន្លែង។
- បានជួសជុលផ្ទាំងប៉ាណូ, លាបថ្នាំផ្ទាំងប៉ាណូសម្រាប់ដាក់តាំងព្រះឆាយាល័ក្ខណ៍ នៅច្រកចេញ-ចូល P1 P2, ធ្វើស្លាក Logo ឈ្មោះបន្ទប់ថ្មី ស្លាកព្រឹទ្ធសភា, បំពាក់នាឡិកាអគ្គិសនីនៅអគារក្រហម, និងបិទក្រដាសជញ្ជាំងបន្ទប់ជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ចំនួន១៤ផ្ទាំង/ស្លាក។
- បានក្រាល ជួសជុលថ្មក្រានីត នៅអគារស អគារក្រហម សាលប្រជុំនានា និងសួនច្បារក្រោមដើមជ្រៃ ព្រមទាំងបានសម្អាតម៉ាបតាមកាំជណ្តើរ នៅអគារ D.E.F ចំនួន១៣កន្លែង។
- បានបំពាក់កញ្ចក់សុវត្ថិភាពតាមកែងផ្លូវ ស្លាកសញ្ញាបន្ថយល្បឿន និងបំពាក់ឆត្រ តុ កៅអី និងដំបងពិល សម្រាប់នគរបាលការពារច្រកចេញ-ចូល P2, P3 ជូនអង្គភាពការពារព្រឹទ្ធសភា ចំនួន២២គ្រឿង/ស្លាក។
- បានពង្រីកចំណតរថយន្តក្រោមដើមជ្រៃ និងរៀបចំចំណតថ្មីសម្រាប់រថយន្តអគ្គិសនីនៅខាងក្រោយអគារ F។
- បានទិញព្រំខ្សែថ្មីសម្រាប់ក្រាលតាមកម្មវិធីនានា នៅអគារក្រហម ចំនួន៥៥ម៉ែត្រ។
- បានប្តូរខ្សែចងដងទង់ជាតិនៅមុខអគារក្រហម ចំនួន១៥ដើម។
- បានសហការជាមួយក្រុមការងារស្ថាបត្យករ **លោក វណ្ណ ម៉ូលីវណ្ណ** ធ្វើការវាស់វែងអគារដែលជាស្ថាបត្យកម្មចាស់ មានដូចជា អគារក្រុមប្រឹក្សាធម្មនុញ្ញ អគារក្រុមប្រឹក្សានៃអង្គចៅក្រម និងអគារសហភាពសហព័ន្ធយុវជនកម្ពុជា។
- បានសហការជាមួយអគ្គិសនីកម្ពុជា លើកត្រង់ស្វូទូសុវត្ថិភាព និងចាក់សាបឱ្យបានខ្ពស់។
- បានសហការជាមួយអង្គភាពលូទឹកនៃមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ ដើម្បីបូមស្អារប្រព័ន្ធលូ និងសាងសង់អាងរំដោះទឹកនៅខាងក្រោយអគារជប៉ុនJ2។
- បានសម្អាតទទឹក និងដំបូល នៅតាមអគារថ្នាក់ដឹកនាំព្រឹទ្ធសភា សាលប្រជុំ និងអគារ D.E.F និង
- បានជួសជុល បាញ់ថ្នាំធុងសំរាមថ្មី ដែកសង្កត់ព្រំ កងព្រំ និងសោទ្វារ នៅអគារស អគារក្រហម និងសាលពិសេស ចំនួន២១៥គ្រឿង/ដើម។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន២,០៥៨គ្រឿង/លើក។
- បានស្រាវជ្រាវ និងរៀបចំចងក្រងសៀវភៅវិមានសាមគ្គីភាព ដែលបរិយាយអំពីការប្រើប្រាស់អគារកេរដំណែល និងប្រវត្តិសាស្ត្រមួយចំនួន នៅក្នុងទីតាំងវិមានរដ្ឋចំការមន។
- បានស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងអគារនៃវិមានរដ្ឋចំការមន នៅបណ្ណាល័យនៃមជ្ឈមណ្ឌលខេមរភាសាសិក្សា (Center of Khmer Studies-CKS) និងវិទ្យាស្ថានបារាំងចុងបូព៌ាប្រទេស (EFEO) នៅខេត្តសៀមរាប។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារវិមានសាមគ្គីភាពនៃព្រឹទ្ធសភា រៀងរាល់ ២សប្តាហ៍ម្តង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានរៀបចំឯកសារស្នើសុំជម្រះបញ្ជីរថយន្តព្រឹទ្ធសភា និងរៀបចំបែបបទឯកសារស្នើសុំគោលការណ៍ប្រគល់រថយន្តជូនអតីតប្រធានគណៈកម្មការ ចំនួន៧គ្រឿង។
- បានរៀបចំឯកសារស្នើសុំជម្រះបញ្ជីរថយន្តព្រឹទ្ធសភា ចំនួន៣គ្រឿង។
- បានធ្វើស្លាកលេខរថយន្តខ្នាតវែង ជូនសមាជិកព្រឹទ្ធសភា ចំនួន៤គ្រឿង។
- បានរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ឆ្នាំគោល (ឆ្នាំ២០២៤) របស់ព្រឹទ្ធសភា ចំនួន១៨ក្បាល។
- បានរៀបចំបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋរបស់ព្រឹទ្ធសភា នៅក្នុងប្រព័ន្ធ SARMIS និងរៀបចំបែបបទជម្រះបញ្ជីអគារចាស់ដើម្បីយកទីតាំងសម្រាប់សាងសង់អគារថ្មីនៃព្រឹទ្ធសភា។
- បានរៀបចំចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភាតាមប្រព័ន្ធ FMIS និងបានរៀបចំតារាងកើន-ថយទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣, លើកទី៣ និងលើកទី៤ នីតិកាលទី៥ ចំនួន២លើក។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមករា-ខែធ្នូ ប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ចំនួន១៤លើក។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា-ខែធ្នូ ប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៥ ចំនួន២៨លើក ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥ ចំនួន២៤លើក។

## ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន២៥០ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានសម្រួលបែបបទ និងនីតិវិធីរៀបចំស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាជាមួយគណៈកម្មការទី៦។
- បានរៀបចំឯកសារជំនួយស្មារតីសម្រាប់កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ លេខាធិការសម័យប្រជុំ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងគណៈកម្មការបោះឆ្នោត ចំនួន៧០លើក។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៦០លើក។
- បានប្រមូលផ្តុំចងក្រងឯកសារ លិខិតបទដ្ឋាននានា និងបោះពុម្ពសៀវភៅស្តីពី៖
  - បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។
  - កំណត់ហេតុពិស្តារ និងសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ (ឆ្នាំ២០២៤)។
  - ច្បាប់លក្ខន្តិកៈសមាជិកព្រឹទ្ធសភា និង
  - ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជរដ្ឋសភា និងព្រឹទ្ធសភា។
- បានធ្វើបច្ចុប្បន្នភាព ប្រមូលផ្តុំចងក្រងឯកសារនានា រួមមាន៖
  - សម្រង់បញ្ជីឈ្មោះច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមឆ្នាំ និងនីតិកាល។
  - សម្រង់លទ្ធផលសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥។
  - បញ្ជីនៃការដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ និង
  - បច្ចុប្បន្នភាពសមាសភាព លេខទូរសព្ទរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អាណត្តិទី៥។
- បានទទួល និងប្រគល់សៀវភៅច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ភាគ១ ភាគ២ និងភាគ៣ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអង្គភាពពាក់ព័ន្ធ ចំនួន២៣៤ក្បាល។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១២លើក។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា ចំនួន២២លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការ

ទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៤,៣៣៦លើក។

- បានសម្រួលការបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល តាមរបប២ឆ្នាំ សម្រាប់អ្នកទទួលការតែងតាំងថ្មី និងលាឈប់ពីមុខតំណែង ចំនួន២២៥នាក់ និងបន្តនីតិវិធីសម្រាប់បុគ្គលឈ្មោះស្ទួន ចំនួន១៦នាក់ និង
- បានទទួល និងបែងចែកសៀវភៅកម្រងឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយចំនួន៤០០ក្បាល។

### ៥.៤-ការងារស្រាវជ្រាវ៖

- បានសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន៤៥ច្បាប់។
- បានចូលរួមតាមដាន និងបានធ្វើរបាយការណ៍តាមដានសម័យប្រជុំពេញអង្គរដ្ឋសភា ដើម្បីពិនិត្យ និងអនុម័តសេចក្តីព្រាងច្បាប់ ចំនួន៤៦ខាងលើ។
- បានសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីស្តីពី៖
    - ច្បាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, ច្បាប់ក្សយធន និងការវិភាជន៍ថវិកាជាតិដល់រដ្ឋបាលឃុំ-សង្កាត់ ជូនគណៈកម្មការទី២។
    - ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ ការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិឃុំ-សង្កាត់ និងប្រភេទប័ណ្ណ សម្រាប់ប្រើប្រាស់សេវាថែទាំសុខភាព ដោយឥតគិតថ្លៃ នៅមូលដ្ឋានថ្នាក់ក្រោមជាតិ ជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ និង
    - បញ្ហាប្រឈម និងបទដ្ឋានគតិយុត្តពិបាកអនុវត្តនៅមូលដ្ឋានភូមិភាគទី៦ ជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦។
- បានសិក្សាស្រាវជ្រាវ រៀបចំឯកសារ និងធ្វើបទបង្ហាញជូនសមាជិក សមាជិកាព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ និងប្រធានបទនានា ចំនួន១៥លើក/ច្បាប់។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
- បានបញ្ចូលទិន្នន័យ ព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងប្រព័ន្ធមូលទិន្នន័យ ចំនួន៣,០៩៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ២,៦៤៨ព័ត៌មាន និង
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍ក្នុងឆ្នាំ២០២៥ ចំនួន៤៨ច្បាប់។

### ៥.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២០៨លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា

និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន២០,២១៦លើក។
- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន ៣,៤៤០លើក។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៩៣លើក។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃព្រឹទ្ធសភា ចំនួន ៥,៧៦១ប្រធានបទ។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខាងមុខព្រឹទ្ធសភា ចំនួន ១៣៦លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៥ ចំនួន៧,២០០ក្បាល។
- បានផលិត និងផ្សព្វផ្សាយវីដេអូស្តីពី៖
    - វឌ្ឍនភាពការងារឆ្នាំទី១ នីតិកាលទី៥ និង
    - វឌ្ឍនភាពការងារឆ្នាំទី១ របស់ក្រុមសមាជិកាព្រឹទ្ធសភា។
- បានរៀបចំផលិត និងបោះពុម្ព៖
    - សៀវភៅទិនានុលេខន៍របស់ព្រឹទ្ធសភាឆ្នាំ២០២៦ ចំនួន១,៥០០ក្បាល។
    - ប្រតិទិនការងារឆ្នាំ២០២៦ ចំនួន៤៥០ច្បាប់។
    - ប្រតិទិនប្រចាំឆ្នាំ២០២៦ ចំនួន១,៥០០ច្បាប់។
    - ប័ណ្ណរថយន្តចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភាឆ្នាំ២០២៦ ចំនួន១,៦០០សន្លឹក។
- បានសិក្សាស្រាវជ្រាវ រៀបចំឯកសារជំនួយស្មារតី ចងក្រងព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មានស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន៥៥៤ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និង ជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹង ជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន២,១២៤គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធសូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៥៥៥លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច និងសៀវភៅជំនាញផ្សេងៗ ចំនួន ៣៦៦ក្បាល ព្រមទាំងបានដាក់តម្កល់សៀវភៅ ចុះបញ្ជីសៀវភៅ ដាក់លេខកូដសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន២៩៨ក្បាល។
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែង តម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១១-២០១៣ ចំនួន៨,៥៨៥ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិត ទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន៥២៨សំណុំ។

**៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៤២៨លើក។
- បានរៀបចំចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពរ និងលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ លិខិតរំលែកទុក្ខ និងកន្ត្រកផ្កាបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៣៨លិខិត និងចំនួន៦៥កន្ត្រក។
- បានបកប្រែឯកសារ រៀបចំលិខិតឆ្លើយតប រៀបចំឯកសារជំនួយស្មារតី និងរៀបចំឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ១៦៩ច្បាប់/លើក។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតជូនសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងគ្រួសារ ចំនួន១២រូប និងលិខិតឆ្លងដែនផ្លូវការថ្មីជូនទីប្រឹក្សា ថ្នាក់ដឹកនាំ សមាជិកនៃខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា, ជំនួយការថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤២រូប។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមករា-ខែវិច្ឆិកា និងប្រចាំឆ្នាំ២០២៥ ចំនួន១២ច្បាប់។
- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៨២ច្បាប់ និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌ និងចងបដា ពាក្យស្លោក ដាក់តាំងប៉ាណូ ក្នុងឱកាសនៃពិធីបុណ្យជាតិ-អន្តរជាតិ ចំនួន១០លើក។

**៤.៧-ការងារអគ្គាធិការដ្ឋាន៖**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្ដល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៥ ចំនួន២៦៤លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្ដីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្ដល់សេវា ប្រចាំខែមករា-ខែធ្នូ ប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៥ ចំនួន១៤លើក។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្ដែងតាមនាយកដ្ឋាននានា ប្រចាំឆ្នាំ២០២៥ ចំនួន២៤លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។

- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន៤៨៦លើក ប្រចាំសប្តាហ៍ ចំនួន ៤៨លើក ប្រចាំខែមករា-ខែធ្នូ ប្រចាំឆមាសទី១ និងប្រចាំឆ្នាំ២០២៥ ចំនួន១៤លើក ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារឆ្នាំ២០២៦

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង
- ត្រៀមរៀបចំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់នានា។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា និង
- ត្រៀមផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា ចុះបំពេញការងារតាមវិស័យរបស់គណៈកម្មការ និងចុះប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ នៅមូលដ្ឋាននាវិស្សមកាលរបស់ព្រឹទ្ធសភា ឱ្យបានល្អប្រសើរ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖
  - អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ និង
  - អញ្ជើញចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- បន្តទទួលពាក្យបណ្តឹង និងសហការជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច ដើម្បីដោះស្រាយបណ្តឹងជូនប្រជាពលរដ្ឋ។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យប្រពៃណីជាតិ សាសនា និងបុណ្យជាតិ-អន្តរជាតិនានា។
- ត្រៀមរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ លិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា និង

- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអង្គទូតនានានៃបណ្តាប្រទេសជាមិត្ត។
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់ឥស្សរជនជាន់ខ្ពស់បរទេស និងអង្គទូតនានានៃបណ្តាប្រទេសជាមិត្ត នៅព្រឹទ្ធសភា។
- ត្រៀមលក្ខណៈរៀបចំដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញទស្សនកិច្ចផ្លូវការ ចូលរួមកិច្ចប្រជុំ វេទិកា សិក្ខាសាលា និងកម្មវិធីផ្សេងៗ នៅក្រៅប្រទេស។
- ត្រៀមផ្តល់សេវាការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិ ជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា និង
- បន្តសហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមផ្តល់សេវាសំខាន់ៗជាច្រើន ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួន មានជាអាទិ៍៖ កិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ ការងារផ្គត់ផ្គង់ សេវាដឹកជញ្ជូន សេវាច្បាប់ សេវាស្រាវជ្រាវ ពិធីការ និងបដិសណ្ឋារកិច្ច ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ ការងារសាងសង់ ជួសជុល កែលម្អ ថែទាំបរិស្ថាន អនាម័យ និងសន្តិសុខ សណ្តាប់ធ្នាប់ក្នុងបរិវេណព្រឹទ្ធសភា ឱ្យបានល្អ ស្រស់បំព្រង ក្នុងបរិបទសភាបៃតង ដើម្បីឆ្លើយតបទៅនឹងកំណើន និងសំណូមពរ ការងារលើមុខងារស្នូលទាំង៣ និងការងារការទូតសភា ដែលជាមុខងារអាទិភាព សំខាន់មួយក្នុងចំណោមមុខងារអាទិភាពសំខាន់របស់ព្រឹទ្ធសភា នីតិកាលទី៥។
- ត្រៀមរៀបចំពិធីសូត្រមន្ត ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើនអគារថ្មីនៃព្រឹទ្ធសភា និងរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារថ្មី ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- ត្រៀមសហការរៀបចំរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ នីតិកាលទី៥ ឱ្យបានល្អ និងទាន់ពេលវេលា។
- ត្រៀមរៀបចំរបាយការណ៍ទូទាត់ថវិកាប្រចាំឆ្នាំ២០២៥ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

- ត្រៀមកសាង និងការពារគម្រោងថវិកាឆ្នាំ២០២៧ ក្នុងកម្រិតរដ្ឋបាល និងនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ត្រៀមបែងចែកកញ្ចប់ថវិកាឆ្នាំ២០២៧ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធរដ្ឋបាល។
- ត្រៀមអនុវត្តផែនការបណ្តុះបណ្តាល សម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០២៦។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារ ការជួសជុល ថែទាំ កែលម្អបរិស្ថាន អនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មីៗ ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្តែង។
- ត្រៀមចងក្រង និងបោះពុម្ពកំណត់ហេតុសង្ខេប និងកំណត់ហេតុពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំពេញអង្គ រួមទាំងឯកសារលិខិតបទដ្ឋានគតិយុត្តនានា។
- ត្រៀមរៀបចំផលិត និងផ្សព្វផ្សាយៈ
    - ខ្សែវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
    - ទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមករា-ខែធ្នូ ឆ្នាំ២០២៦។
    - ប្រតិទិនការងារឆ្នាំ២០២៧។
    - ប្រតិទិន និងសៀវភៅទិនានុលេខន៍ព្រឹទ្ធសភាឆ្នាំ២០២៧។
    - ប័ណ្ណរថយន្តចេញ-ចូល ក្នុងបរិវេណព្រឹទ្ធសភា ឆ្នាំ២០២៧ និង
    - ខិត្តប័ណ្ណបុណ្យជាតិ។
- បន្តរៀបចំបណ្ណសារដ្ឋានអេឡិចត្រូនិច និង
- បន្តពង្រឹងពង្រីកការងារសេវាគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មានព្រឹទ្ធសភាឱ្យកាន់តែទំនើបប្រកបដោយគុណភាព និងប្រសិទ្ធភាព។

## III-សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម មានប្រសិទ្ធភាព និងទទួលខុសត្រូវខ្ពស់ ដោយគាំទ្រ និងបម្រើដល់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងារទាំង៥ ជាពិសេសមុខងារនីតិកម្ម ការតាមដានការអនុវត្តច្បាប់ កិច្ចការអន្តរជាតិ។ ការរៀបចំកិច្ចប្រជុំ សម័យប្រជុំ ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីស្នើច្បាប់ និងសេចក្តីព្រាងច្បាប់ជាច្រើន បានប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវតាមនីតិវិធី និងចូលរួមលើកកម្ពស់ប្រព័ន្ធនីតិរដ្ឋ។

ជាមួយគ្នានេះ ការចុះតាមដានការងារនៅមូលដ្ឋាន ការជួបពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន បានជួយឱ្យព្រឹទ្ធសភាទទួលបានព័ត៌មានពិតប្រាកដ សម្រាប់ការផ្តល់អនុសាសន៍ និងការសម្រេចចិត្តប្រកបដោយគុណភាព។

ក្រៅពីការងារក្នុងស្ថាប័ន អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងព្រឹទ្ធសភា បានធ្វើសកម្មភាពរួមគ្នាជាមួយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងបុព្វហេតុការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី

និងបាននាំយកអំណោយជាស្បៀងអាហារ សម្ភារប្រើប្រាស់ជូនកងទ័ពនៅសមរភូមិមុខ និងប្រជាពលរដ្ឋភៀសសឹក នៅតាមបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។

សរុបលទ្ធផលការងារឆ្នាំ២០២៥ បានបង្ហាញពីការរីកចម្រើន និងសមត្ថភាពរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការគាំទ្រការអភិវឌ្ឍប្រទេស និងបន្តបំពេញភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពនៅឆ្នាំ២០២៦។

ថ្ងៃសុក្រ ៨កើត ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៦

**អគ្គលេខាធិការ**

**ឡាយ សំកុល**